# កម្ពុជាក្រោម

លេខ ២៨ ឆ្នាំទី ០៣ ខែមេសា គ.ស. ២០០៦ - ព.ស. ២៥៤៩


# លិខិតជូនពរឆ្នាំថ្មី

## របស់លោក តោ គឹមថុង អធិបតីសហព័ន្ធខ្មែរកម្ពុជាក្រោម



លោក តោ គឹមថុង អធិបតីសហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក

សូមថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និង សូមគោរពចំពោះបងប្អូនជនរួមជាតិនៅគ្រប់មជ្ឈដ្ឋាន ដែលកំពុងរស់នៅឯមាតុភូមិកម្ពុជាក្រោម ក៏ដូចជាបងប្អូនខ្មែរដែលកំពុងរស់នៅក្នុងបណ្ដាប្រទេសនានាជុំវិញពិភពលោក ជាទីសក្ការៈ និងស្រឡាញ់រាប់អានយ៉ាងជ្រាលជ្រៅជាទីបំផុត ។

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំច អដ្ឋស័ក ព.ស. ២៥៥០ គ.ស. ២០០៦ នេះ តាងនាមខ្ញុំព្រះករុណាខ្ញុំបាទជាអធិបតី ព្រមទាំងថ្នាក់ដឹកនាំសហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក សូមប្រគេន និងជូនពរបវរមហាប្រសើរ សិរីសួស្ដីសុភមង្គល វិបុលសុខគ្រប់ប្រការ ចូរចំរុងចំរើនកើតមានដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិខ្មែរទាំងអស់គ្រប់ពេលវេលា ។

ឆ្នាំចាស់កន្លងផុតទៅ ដោយបន្សល់ទុកនូវស្នាដៃ និងអនុស្សាវរីយ៍ជាច្រើនសន្ធឹកសន្ធាប់ដែលបងប្អូនជនរួមជាតិបានកសាងទុក ។ ប្រជាជនខ្មែរនៅព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាប្រជាជនខ្មែរនៅបរទេស បានខិតខំថែរក្សាប្រពៃណីទំនៀមទម្លាប់ដ៏ល្អផូរផង់ដែលបុព្វបុរសខ្មែរ លោកបានបន្សល់ទុកឲ្យកូនចៅជំនាន់ក្រោយប្រតិបត្តិតាម ។ ជាក់ស្ដែងក្នុងរដូវបុណ្យចូលឆ្នាំថ្មីនេះ បងប្អូនខ្មែរគ្រប់ទីកន្លែង ក៏ដូចជានៅឯមាតុភូមិកម្ពុជាក្រោមដែរ បានចូលរួមអបអរសាទរ ប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មី យ៉ាងអធិកអធម ទៅតាមប្រពៃណីជាតិ ដើម្បីឧទ្ទិសមគ្គផល ជូនដល់បុព្វការីជន និងបួងសួងដល់ទេវតាឆ្នាំថ្មី ដែលត្រូវជំនួសតំណែងទេវតាឆ្នាំចាស់ មកថែរក្សាមនុស្សលោកនេះ សូមតាមជួយបីបាច់ ថែរក្សា ចម្រុងចម្រើន ឲ្យបានសេចក្ដីសុខ និងបំពេញកិច្ចការអ្វីឲ្យបានសម្រេចដូចក្ដីប្រាថ្នា ។ ដោយឡែកនៅឯកម្ពុជាក្រោមឯណោះវិញ ពិតមែនតែជនរួមជាតិ កំពុងរស់នៅក្រោមការភិតភ័យ គាបសង្កត់ បំផ្លិចបំផ្លាញ និង រំលោភបំពានបំបិទសិទ្ធិសេរីភាពខាងជំនឿ ដែលជាគោលការណ៍របស់រដ្ឋាភិបាលយួនកុម្មុយនិស្តឥតសាសនា ក្នុងគោលបំណងធ្វើឲ្យជីវភាពរស់នៅរបស់បងប្អូនជនរួមជាតិរស់នៅកាន់តែមានភាពទ័លក្រ និងជួបប្រទះវិបត្តិគ្មានពេលល្ហែក៏ដោយ ក៏គួរឲ្យកោតសរសើរយ៉ាងក្រៃលែងចំពោះជនរួមលោហិត ដែលនៅតែប្រកាន់ខ្ជាប់នូវសតិសម្បជញ្ញៈរបស់ខ្លួន ប្រកបដោយមនសិការជាតិដ៏ឧត្តុង្គឧត្តម ស្របទៅនឹងគោលការណ៍របស់សហព័ន្ធខ្មែរកម្ពុជាក្រោមដែលអនុវត្តនូវមាគ៌ាអហិង្សា ដើម្បីទាមទារសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ។

ឆ្នាំថ្មីនេះ ជាឱកាសសម្រាប់ឲ្យយើងសាកល្បង នូវគំនិតថ្មី ដើម្បីស្វែងរកសេចក្ដីសន្ដោស យោគយល់ អំណត់អត់ធន់ និងអនុវត្តនូវសច្ចភាពចំពោះការទំនាក់ ***(តទៅទំព័រទី ៣)***

### មាតិការឿង


- លិខិតប្រគេន និងជូនពរឆ្នាំថ្មី........................១
- ញ្ញើនៅនឹងថ្នក់ ទំពក់នៅនឹងដៃ....................២
- អាជ្ញាធរយួនបដិសេធ..................................៤
- និស្សិតខ្មែរក្រោមមិនបានឈប់សំរាក............៥
- សម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរ..................៦
- រកឃើញឧបករណ៍ថតសំឡេង.....................៨
- អាថ៌កំបាំងនៅជាន់ទី ២..............................១១
- កំណាព្យ "ជីវិតជាទាហានអាមេរិក"...........១៣
- សេចក្ដីអំពាវនាវរបស់សហព័ន្ធ...................១៥

# ញ្ញៀនៅនឹងថ្នក់ ទំពក់នៅនឹងដៃ យួនក្រឡាស់ម្ដេចនឹងរួច

ក្រសួងការបរទេសអាមេរិក បានប្រកាសជាសាធារៈណៈនូវរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនកាលពីថ្ងៃទី ០៨ មីនា ឆ្នាំ ២០០៦ ស្ដីអំពីស្ថានភាពសិទ្ធិមនុស្សនៅលើពិភពលោក ដែលរួមមាន ១៩៦ ប្រទេស ។ របាយការណ៍នេះ ត្រូវបានចងក្រង និងរាយការណ៍ជូនសភាអាមេរិកកាំង ចាប់តាំងពីឆ្នាំ ១៩៧៧ មក ។

ដោយឡែកពីប្រទេសវៀតណាម របាយការណ៍របស់ក្រសួងការបរទេសអាមេរិកកាំងឆ្នាំនេះបានសង្កត់ធ្ងន់ថា របាយការណ៍សិទ្ធិមនុស្សរបស់រដ្ឋាភិបាលវៀតណាម មិនបានបង្កការពេញចិត្តនៅឡើយទេ បើទោះបីជាមានការកែប្រែក្នុងឆ្នាំកន្លងទៅក៏ដោយ ។ មូលហេតុនៃរបាយការណ៍នេះធ្វើឲ្យយួនខំបង្កើងនូវសន្និសីទសារព័ត៌មានមួយកាលពីថ្ងៃទី ៩ មីនា រកលេសដោះសារយ៉ាងវិលក្បុង ដើម្បីយករួចខ្លួន ។ តែទោះជាខំយ៉ាងណាក៏មិនរួចខ្លួនដែរ ព្រោះញ្ញៀនៅនឹងថ្នក់ ទំពក់នៅនឹងដៃទៅហើយ ។

របាយការណ៍របស់ក្រសួងការបរទេសអាមេរិកឆ្នាំនេះរាយការណ៍ថា "រដ្ឋាភិបាលវៀតណាម នៅតែបង្កសម្ពាធគំរាមកំហែង និងដាក់គុកអ្នកទាំងឡាយណា ដែលហ៊ានសំដែងទស្សនៈនយោបាយ ឬ ទស្សនៈសាសនា ទោះជាតាមរូបភាពអហិង្សាក៏ដោយ" ។ របាយការណ៍បានបន្ថែមទៀតថា ច្បាប់របស់វៀតណាម អនុញ្ញាតឲ្យមានសេរីភាពបញ្ចេញមតិ និងសារព័ត៌មាន ប៉ុន្តែជាតុពិត រដ្ឋាភិបាលវៀតណាម នៅតែហាមប្រាមនូវការបញ្ចេញមតិ ដាក់ជាសំណួរអំពីតួនាទីរបស់បក្សកុម្មុយនិស្ត រិះគន់អ្នកដឹកនាំ ឬ ការផ្សព្វផ្សាយពហុទ្រឹស្ដី និងបញ្ហាប្រជាធិបតេយ្យពហុបក្សជាដើម ។

នៅក្នុងសន្និសីទសារព័ត៌មាន នាឱកាសប្រកាសរបាយការណ៍សិទ្ធិមនុស្សនៅ វ៉ាស៊ីនតោន កាលពីថ្ងៃទី ០៨ មីនា លោក ព្រីឡូវៃនក្រួន ជាជំនួយការរបស់រដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិកកាំង ដែលលោកទើបតែនឹងវិលត្រឡប់ទៅពីប្រទេសវៀតណាម លោកបានសន្និដ្ឋានថា"វៀតណាម កំពុងតែជម្រុញទំនាក់ទំនងជាមួយនឹងអាមេរិក" ។ លោកបានបញ្ជាក់អំពីរឿងទំនាក់ទំនងនេះថា "ការជម្រុញទំនាក់ទំនងវៀតណាមក៏ត្រូវការចូលរួមឲ្យមានភាពជឿនលឿនខាងសិទ្ធិមនុស្សដែរ" ។ លោកបន្តទៀតថា អ្នកកាន់តំណែងមុនលោក បានផ្អាកការជជែកជាមួយវៀតណាម នៅឆ្នាំ ២០០២ ព្រោះគេឃើញថាពុំមានលទ្ធផល ។ តែចំពោះលោក លោកមានកិច្ចប្រជុំដ៏ល្អប្រសើរជាមួយវៀតណាម តែនេះពុំមែនមានន័យថា រាល់បញ្ហាត្រូវបានដោះស្រាយនោះទេ ព្រោះវាគ្រាន់តែជាការចាប់ផ្ដើមតែប៉ុណ្ណោះ ។

ចំពោះរឿងរ៉ាវរំលោភសិទ្ធិមនុស្សរបស់កុម្មុយនិស្តយួនសព្វថ្ងៃវាដូចជារបាយការណ៍របស់ក្រសួងការបរទេសអាមេរិកបានរាយការណ៍អ៊ីចឹង គឺថាតាមច្បាប់របស់យួន គេមានចែងអំពីការគោរពសិទ្ធិមនុស្សច្បាស់លាស់ តែជាតុពិត គឺគេមិនបានអនុវត្តច្បាប់ដែលគេបានចែងនោះទេ ។ ច្បាប់ និងធម្មនុញ្ញរបស់យួនគ្រាន់តែដាក់លម្អឲ្យសហគមន៍អន្តរជាតិមើលសប្បាយភ្នែកតែប៉ុណ្ណោះ ។

គេនៅចាំបានថា កាលពីពាក់កណ្ដាលឆ្នាំ ២០០៤ វៀតណាម បានបង្ក្រាបបាតុកម្មរបស់ក្រុមកុលសម្ព័ន្ធភ្នំម៉ុងតាញ៉ានៅភូមិភាគកណ្ដាលនៃប្រទេសវៀតណាម យ៉ាងសាហាវឃោរឃៅបំផុត រហូតដល់មានការសម្លាប់មនុស្សក្រៅប្រព័ន្ធច្បាប់ទៀតផង ។

នៅថ្ងៃទី ២៤ មីនា ឆ្នាំ ២០០៥ អាជ្ញាធរយួននៅខេត្តព្រះត្រពាំង បានចាប់ផ្សឹកភិក្ខុសង្ឃខ្មែរមួយអង្គនាម ថាច់ លីភោ ដែលគ្រាន់តែសង្ឃអង្គនេះ ចែកគ្នាមើល ចែកគ្នាអាន នូវព្រឹត្តិបត្រសហព័ន្ធខ្មែរកម្ពុជាក្រោម និងសៀវភៅឯកសារដទៃទៀតដែលទាក់ទិននឹងសោកនាដកម្មរបស់ខ្មែរក្រោម ។

ភិក្ខុ ថាច់ ប្រីជាគឿន ជាតំណាងជនភៀសខ្លួនខ្មែរក្រោម ដែលរត់ភៀសខ្លួនទៅជ្រកកោននៅទីក្រុងភ្នំពេញ បានប្រាប់ទៅវិទ្យុសំឡេងសហរដ្ឋអាមេរិក (VOA) និងវិទ្យុអាស៊ីសេរីជាភាសាខ្មែរផង ជាភាសាវៀតណាមផង កាលពីថ្ងៃទី០៤ សីហា

និពន្ធនាយក ៖ **ថាច់ ចន្ទ** ផ្សព្វផ្សាយ ៖ **សឺន រតនៈ, សឺន ច័ន្ទ**
ឯកសារ PDF មាននៅក្នុងគេហទំព័រ www.khmerkrom.net

ឆ្នាំ ២០០៥ ថា មូលហេតុដែលខ្មែរក្រោមរត់ភៀសខ្លួនទៅកម្ពុជាជាង ១០០ នាក់នេះ គឺគេចពីការធ្វើទុក្ខបុកម្នេញពីរបបកុម្មុយនិស្តយួន ។

ព្រះអង្គផ្ទាល់គេចខ្លួនទៅកម្ពុជានេះ ព្រោះព្រះអង្គជាដៃគូរបស់ភិក្ខុ ថាច់ លីភោ ទើបពួកអាជ្ញាធរយួនបានតាមចាប់ខ្លួនព្រះអង្គ និងសំឡុតគំរាមកំហែងដល់ឪពុកម្តាយព្រះអង្គទៀតផង ។

ភិក្ខុ ថាច់ សារុម មានស្រុកកំណើតនៅខេត្តព្រះត្រពាំង ដែលជាជនភៀសខ្លួនមួយអង្គដែរ បានមានថេរដីកាឲ្យដឹងថា "ព្រះអង្គជាសមណនិស្សិតនៅសាលាបាលីខេត្តឃ្លាំង ព្រះអង្គភៀសខ្លួនទៅកម្ពុជា ព្រោះតែការបំបិទសិទ្ធរបស់យួនកុម្មុយនិស្តមិនឲ្យព្រះអង្គ និងសមណនិស្សិតអង្គផ្សេង ៗ ទៀតស្តាប់វិទ្យុអាស៊ីសេរី វិទ្យុសំឡេងសហរដ្ឋអាមេរិក និងវិទ្យុសំឡេងកម្ពុជាក្រោម ព្រមទាំងហាមមិនឲ្យទាក់ទងនឹងជនបរទេស ឬ ខ្មែរនៅក្រៅប្រទេសតាមរយៈទូរស័ព្ទ ឬ តាមប្រព័ន្ធអ៊ិនធឺណែតទៀតផង" ។

ភិក្ខុ ថាច់ សារុម បានបន្តទៀតថា "យួនគេអនុញ្ញាតឲ្យមានសាលារៀនភាសាខ្មែរតាមវត្តអារាម តាមភូមិស្រុកខ្មែរមួយចំនួន តែគេមិនបានអនុញ្ញាតឲ្យខ្មែរប្រើប្រាស់ភាសាខ្មែរ អក្សរខ្មែរជាសាធារណៈទោះទេ" ។ ដូច្នេះ ការប្រឡងដំណាច់ឆ្នាំនៅសាលារបស់ព្រះអង្គម្តង ៗ ប្រធានបទវិញ្ញាសាប្រឡងជាភាសាខ្មែរ តែបែរជាបង្ខំឲ្យសិស្សបរិយាយជាភាសាយួនទៅវិញ ។

លោក សឺន ថាញ់ អាយុ ៤៥ ឆ្នាំ ជាពុទ្ធបរិស័ទចំណុះជើងវត្តព្រៃកជ្រៅ ក្នុងស្រុកវិញឡើយ ខេត្តពលលាវ នៅចុងខែមិថុនា ឆ្នាំ ២០០៥ ប្តីប្រពន្ធគាត់បានធ្វើលិខិតសុំច្បាប់ទៅភ្នំពេញ ។ លោកបានស្នាក់នៅភ្នំពេញអស់រយៈពេលមួយខែ ២១ ថ្ងៃ លុះដល់ថ្ងៃទី ១ ខែសីហា ឆ្នាំ ២០០៥ ប្តីប្រពន្ធគាត់បានត្រឡប់មកដល់ផ្ទះវិញ ហើយក៏ត្រូវបានអាជ្ញាធរមូលដ្ឋាននោះហៅទៅគំរាមកំហែង ចោទប្រកាន់ដោយបំពានថា ប្តីប្រពន្ធរបស់លោកពាក់ព័ន្ធរឿងនយោបាយរបស់ខ្មែរក្រោម ហើយពួកអាជ្ញាធរមូលដ្ឋានបានបង្ខំឲ្យប្តីប្រពន្ធលោក ថាញ់ ឆ្លើយបំផ្លើសការពិត ទម្លាក់កំហុសទៅលើសកម្មជនរបស់សហព័ន្ធខ្មែរកម្ពុជាក្រោមនៅកម្ពុជា និងក្រៅប្រទេស ។ បើប្រសិនជាប្តីប្រពន្ធលោកមិនព្រមឆ្លើយតាមអ្វីដែលគេបានបង្គាប់ទេនោះ គេនឹងរកលេសដាក់ទោសប្តីប្រពន្ធលោកឲ្យកាន់តែធ្ងន់ថែមទៀត ។

តាមការត្អូញត្អែររបស់លោក ថាញ់ លួចប្រាប់ឲ្យដឹងថា "លោកមិនហ៊ានតវ៉ានឹងគេទេ ព្រោះប្តីប្រពន្ធលោកបានយករឿងដែលអាជ្ញាធរយួនរំលោភបំពានមកលើរូបលោក និងប្រជាជាតិខ្មែរក្រោមទៅប្តឹងដល់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ដែលមានទីស្នាក់ការនៅឯភ្នំពេញនោះពិតមែន" ។ ហេតុនេះដើម្បីឲ្យបានរស់សុខខ្លួន លោកចេះតែឆ្លើយឲ្យរួចខ្លួនមួយគ្រា ៗ តែប៉ុណ្ណោះ ។

របាយការណ៍ស្តីអំពីសិទ្ធិមនុស្សនៅវៀតណាម ដូចដែលរបាយការណ៍របស់ក្រសួងការបរទេសអាមេរិកកាំង រាយការណ៍នៅថ្ងៃទី ០៨ មីនា នេះ ក៏ដូចជារបាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) បានរាយ-ការណ៍រួចហើយកាលពីថ្ងៃ ១៧ មករា ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅវៀតណាម នៅតែត្រូវបានរំលោភបំពានជាដដែល ៕

***(តមកពីទំព័រទី ១)*** ទំនងរវាងគ្នា និងគ្នា ដែលជាវិធីមួយអាចនាំមកនូវដំណោះស្រាយជាវិជ្ជមាន និងស្របទៅនឹងគោលការណ៍សហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក គឺប្រមូលមិត្ត ហើយបន្ថយសត្រូវ រួមកម្លាំងកាយ កម្លាំងចិត្ត សតិបញ្ញា រិះរកមាគ៌ាដ៏ត្រឹមត្រូវរក្សាគោលជំហរយ៉ាងម៉ឺងម៉ាត់ កសាងសង្គមខ្មែរក្រោមឲ្យមានប្រសិទ្ធភាព និងឈានទៅដល់ទិសដៅនៃគោលការណ៍របស់យើងទាំងអស់គ្នា ។ យើងទាំងអស់គ្នា ត្រូវរួបរួមកម្លាំងសាមគ្គីជានិច្ច មិនត្រូវបែកបាក់ដោយពាក្យញុះញង់របស់គេឡើយ ។ សុភាសិតខ្មែរបានពោលថា "ឈ្លោះគ្នាក្នុងគ្រួសារដូចស្រាតកាយាបង្ហាញញាតិ ឈ្លោះគ្នាក្នុងសង្គមជាតិដូចលាតកំណាប់បង្ហាញចោរ"។ នេះគឺជាគតិធម៌របស់ដូនតាយើងបន្សល់ទុកមក សម្រាប់ឲ្យយើងជាខ្មែរ ជាពិសេសសម្រាប់ថ្នាក់ដឹកនាំគ្រប់រូបពិចារណា និងជៀសវាងផងដែរ ។

ជាទីអវសាន ខ្ញុំព្រះករុណាខ្ញុំបាទ សូមបួងសួងដល់គុណបុណ្យព្រះរតនៈត្រៃ និងទេវតាឆ្នាំថ្មីព្រះនាង កិមិរាទេវី សណ្តោសចិត្តមនុស្សលោកឲ្យចេះគោរព និង ស្រឡាញ់គ្នា ហើយសូមឲ្យពិភពលោកបានប្រកបទៅដោយសន្តិភាព និង វឌ្ឍនភាពជានិច្ចជានិរន្តរ៍ ៕

សូមអរព្រះគុណ និង អរគុណ !

អធិបតីសហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក

**តោ គីមថុង**

# អាជ្ញាធរយួនបដិសេធការបើកសាលាពុទ្ធិកសិក្សានៅវត្តជីក្អែង

ថ្មី ៗ នេះ យោងតាមប្រភពព័ត៌មានពីព្រះសង្ឃ និងពុទ្ធបរិស័ទចំណុះជើងវត្តរំដួលទួលសុភរីរាម ហៅ ជីក្អែងក្រោម ស្ថិតក្នុងស្រុកស្វាយទង ខេត្តមាត់ជ្រូក បានឲ្យដឹងថា អាជ្ញាធរកុម្មុយនិស្តយួន នៅតែរឹតបន្តឹងចំពោះវិស័យអប់រំផ្នែកអក្សរ-សាស្ត្រខ្មែរជាដដែល ។ កន្លងទៅថ្មី ៗ នេះ វត្តជីក្អែងក្រោម បានធ្វើសេចក្តីស្នើសុំបើកសាលាពុទ្ធិកសិក្សានៅថ្ងៃ ១៥ កើត ខែពិសាខ ឆ្នាំច ត្រូវនឹងថ្ងៃសុក្រទី ១២ ខែឧសភា ឆ្នាំ ២០០៦ ខាងមុខ តែត្រូវបានអាជ្ញាធរកុម្មុយនិស្តយួនបដិសេធទាំងស្រុង ។

តាមការឲ្យដឹង របស់ពុទ្ធបរិស័ទចំណុះជើងវត្តជីក្អែងក្រោម និងព្រះសង្ឃគង់នៅខេត្តមាត់ជ្រូក បានផ្តល់ដំណឹងដល់អ្នកយកព័ត៌មានព្រឹត្តិបត្រកម្ពុជាក្រោមថា សព្វថ្ងៃនេះ អាជ្ញាធរយួនកាន់តែរឹតបន្តឹងចំពោះវិស័យអប់រំខាងពុទ្ធចក្រ សំខាន់គឺថ្នាក់ពុទ្ធិកសិក្សាដែលព្រះសង្ឃ និងកូនចៅខ្មែររៀននៅក្នុងវត្តតែម្តង ។ ផ្ទុយទៅវិញ អាជ្ញាធរកុម្មុយនិស្តយួន បែរជាបើកចំហឲ្យកម្មាភិបាលយួនរៀនអក្សរសាស្ត្រខ្មែរទៅវិញ ដែលជារឿងចំឡែកមួយគួរឲ្យចាប់អារម្មណ៍ ។ ករណីជាក់ស្តែង គឺវត្តជីក្អែងក្រោម ដែលបានដាក់សំណើបើកថ្នាក់ពុទ្ធិកសិក្សានៅថ្ងៃ ១៥ កើត ខែពិសាខ ឆ្នាំច ខាងមុខ ត្រូវបានរដ្ឋអំណាចយួនបដិសេធសំណើសុំទាំងស្រុង ។

ទាក់ទិននឹងបញ្ហានេះ ភិក្ខុព្រះនាម ថៅ ទេព ព្រះជន្មប្រមាណ ៣០ វស្សា គង់នៅក្នុងវត្តមួយក្នុងខេត្តមាត់ជ្រូក កម្ពុជាក្រោម ។ ព្រះអង្គទើបវិលត្រឡប់មកពីបំពេញវិជ្ជានៅខេត្តព្រះត្រពាំង គឺទើបបញ្ចប់ថ្នាក់ពុទ្ធិកសិក្សាសាលាបាលីរងថ្មី ៗ នេះ ដោយមានសង្ឃដីកាទៅកាន់អ្នកយកព័ត៌មានថា "អាត្មាមានសេចក្តីសោកស្តាយយ៉ាងខ្លាំង ចំពោះអាជ្ញាធរយួនកុម្មុយនិស្ត ដែលមិនព្រមអនុញ្ញាតឲ្យវត្តជីក្អែងក្រោម បើកសាលាពុទ្ធិកសិក្សាថ្នាក់ទី ៣ ព្រោះនៅខេត្តមាត់ជ្រូកនេះ ខ្សត់ខ្លាំងណាស់ វត្តឯទៀត ៗ ក៏ពុំមានសមត្ថភាពបើកឡើយ ដោយសារពុំមានគ្រូអាចារ្យគ្រប់គ្រាន់ និងពិបាកក្នុងការរកកន្លែងស្នាក់នៅសម្រាប់ព្រះសង្ឃមកពីចម្ងាយ ។ ម្យ៉ាងទៀតក្នុងខេត្តមាត់ជ្រូក ពុំមានសាលាពុទ្ធិកសិក្សាច្រើនដូចជាខេត្តដទៃ ៗ ទៀតនោះទេ ។ ដូច្នេះ ការបដិសេធរបស់អាជ្ញាធរយួនទំនងជាពួកគេមិនចង់ឲ្យព្រះសង្ឃក្នុងខេត្ត មានទំនាក់ទំនងនឹងព្រះសង្ឃនៅខេត្តព្រះត្រពាំង ឬខេត្តឯទៀត ៗ មើលទៅ" ។ ព្រះអង្គ ថៅ ទេព បានបន្តទាំងព្រះទ័យមិនរីករាយចំពោះបញ្ហានេះ ដោយព្រះអង្គបានចោទជាសំនួរថា "បើពួកអាជ្ញាធរយួនមិនព្រមអនុញ្ញាតឲ្យព្រះសង្ឃ បើកសាលា និងមិនឲ្យកូនចៅខ្មែររៀនអក្សរខ្មែរ ចុះហេតុអ្វីបានជាពួកគេបែរជាបើកកម្មវិធីបង្រៀនអក្សរខ្មែរដល់ពួកកម្មាភិបាលយួន ឬក៏គេមានល្បិចអ្វីទេដឹង ?" ។



ចំណែកឯលោកតាគណៈកម្មការវត្តខាងលើ ដែលមានអាយុប្រមាណ ៦០ ឆ្នាំ សព្វថ្ងៃលោកតាស្នាក់នៅក្នុងភូមិជីក្អែង ស្រុកស្វាយទង ខេត្តមាត់ជ្រូក បានបង្ហើបឲ្យដឹងថា "ចាប់តាំងពីមានករណីរត់គៀសខ្លួនរបស់អតីតព្រះចៅអធិការវត្តទៅកម្ពុជាមក អាជ្ញាធរយួនរឹតបន្តឹងយ៉ាងខ្លាំងទៅលើសកម្មភាពរបស់គណៈកម្មការ ព្រះសង្ឃក្នុងវត្ត និងពុទ្ធបរិស័ទណាដែលធ្លាប់មកវត្តមានទំនាក់ទំនងនឹងព្រះចៅអធិការ ដោយពួកអាជ្ញាធរយួន តែងមកវត្តគំរាមកំហែងព្រះសង្ឃ និងគណៈកម្មការ វត្តជារឿយ ៗ ។ ករណីជាក់ស្តែង ពួកអាជ្ញាធរយួនប្រើអំណាចផ្តាច់ការតែម្តង ដោយចង់កោះហៅព្រះសង្ឃអង្គណា ឬគណៈកម្មការណាទៅសាលាឃុំក៏ស្រេចតែចិត្តគេ ។ ម្យ៉ាងទៀតព្រះចៅអធិការវត្ត ត្រូវបានអាជ្ញាធរឃុំចូវឡាំងកោះហៅជាញឹកញាប់ ។ លើសពីនោះ ករណីសុំបើកសាលាតែម្តង គឺពួកគេបានបដិសេធដោយពុំមានហេតុផលអ្វីសោះ" ។

បន្ទាប់ពីបានបង្ហើបប្រាប់អ្នកយកព័ត៌មាន លោកតាក៏បានសុំអំពាវនាវដល់សហព័ន្ធខ្មែរកម្ពុជាក្រោម និងសហគមន៍អន្តរជាតិ ជួយរកយុត្តិធម៌ជូនបងប្អូនខ្មែរក្រោម ដែលកំពុងត្រូវយួនរើសអើងពូជសាសន៍នោះផង ។ ខ្មែរជាជនជាតិដើម បែរជាយួនមិនអនុញ្ញាតឲ្យរៀនអក្សរសាស្ត្រខ្មែរ ប្រវត្តិសាស្ត្រខ្មែរ ហើយបែរជាបើកដៃឲ្យពួកយួនរៀនទៅវិញ ។

ទាក់ទិននឹងករណីអាជ្ញាធរយួនបដិសេធ ក្នុងការបើកសាលាពុទ្ធិកសិក្សានេះដែរ អ្នកយកព័ត៌មានយើងខ្ញុំ មិនអាចធ្វើការទាក់ទង និង សុំសេចក្តីអធិប្បាយពីសំណាក់ព្រះចៅអធិការវត្តបានឡើយ ដោយសង្កេតឃើញ ព្រះអង្គត្រូវបានអាជ្ញាធរយួនឃុំចូវឡាំងកោះហៅទៅសាលាឃុំជាញឹកញាប់ និងកំពុងស្ថិតក្រោមការគំរាមកំហែងផងដែរ ៕ ស្រីវ័ន្ត

# និស្សិតខ្មែរក្រោមមិនបានឈប់សំរាកក្នុងថ្ងៃបុណ្យចូលឆ្នាំថ្មី



ទិដ្ឋភាពនិស្សិតមិនសប្បាយចិត្ត នៅមុខមហាវិទ្យាល័យខេត្តអានយ៉ាង

យោងតាមប្រភពព័ត៌មានដែលទទួលបានពីនិស្សិតខ្មែរកំពុងសិក្សានៅសាលាមហាវិទ្យាល័យខេត្តអានយ៉ាង ឬមាត់ជ្រូកនោះ បានឲ្យដឹងថា ថ្មី ៗ នេះ នាយកមហាវិទ្យាល័យលោក វ៉រ តាំស៊ុង (Vo Tam Xuan) បានគំរាមកំហែងមិនឲ្យនិស្សិតខ្មែរក្រោមឈប់សំរាកដើម្បីបានចូលរួមអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិនោះឡើយ ដែលផ្ទុយស្រឡះកាលពីថ្ងៃបុណ្យចូលឆ្នាំយួន សាលាបានអនុញ្ញាតឲ្យនិស្សិតសម្រាកដល់ទៅមួយសប្ដាហ៍ ។ ចំណែកក្នុងកំឡុងបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរនេះ បើនិស្សិតរូបណាហ៊ានឈប់សម្រាកត្រឹមតែមួយថ្ងៃ សាលានឹងមិនអនុញ្ញាតឲ្យប្រឡងឆមាសទីពីរ ឬ ត្រូវបណ្ដេញចេញពីសាលាតែម្ដង ។

និស្សិតឈ្មោះ ចៅ វាសនា ភេទប្រុស អាយុ ១៩ ឆ្នាំ មានស្រុកកំណើតនៅស្រុកស្វាយទង ខេត្តមាត់ជ្រូក ។ សព្វថ្ងៃប្អូនជានិស្សិតឆ្នាំទីមួយ សិក្សាជំនាញគីមី បានឲ្យដឹងថា "ថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខាងមុខនេះ ពួកប្អូនមិនបានឈប់សម្រាកដើម្បីទៅផ្ទះជួបជុំគ្រួសារ និង ចូលរួមអបអរសាទរអំណរបុណ្យចូលឆ្នាំនោះទេ ដោយលោកនាយកសាលាគេមិនអនុញ្ញាតឲ្យឈប់សម្រាកឡើយ ។ បើនិស្សិតរូបណាសម្រាកដោយឯកឯងនោះ នឹងត្រូវសាលាបម្រាមមិនឲ្យប្រឡងឆមាសទីពីរ ឬត្រូវបណ្ដេញចេញពីសាលាភ្លាម" ។ ប្អូន ចៅ វាសនា បានបន្តទាំងក្ដីសោកសៅទៀតថា "ប្អូនក៏ដូចជាមិត្តភ័ក្តិឯទៀតមានសេចក្ដីសោកស្ដាយខ្លាំងណាស់ មកដល់ពេលនេះហើយរដ្ឋអំណាចយួននៅតែរើសអើងពូជសាសន៍ទៀត" ។

ចំណែកឯនិស្សិត នាង សុខគន្ធា សព្វថ្ងៃកញ្ញាស្នាក់នៅផ្ទះជួលជិតសាលា កញ្ញាមានដើមកំណើតនៅភូមិអូរឡើម ស្រុកស្វាយទង ខេត្តមាត់ជ្រូក កញ្ញាមានអាយុប្រមាណ២៣ ឆ្នាំ ជានិស្សិតឆ្នាំទី ៤ នៃមហាវិទ្យាល័យខេត្តអានយ៉ាង សិក្សាជំនាញអក្សរសាស្ត្រយួន បានបង្ហើបឲ្យដឹងថា "កញ្ញាក៏មានសេចក្ដីសោកស្ដាយខ្លាំងណាស់ដែរ ចំពោះករណីបែបនេះ ព្រោះអីសព្វថ្ងៃប្រពៃណីខ្មែរនៅកម្ពុជាក្រោមកំពុងត្រូវបានយួនបំពាន ដោយគេមិនអនុញ្ញាតឲ្យកូនចៅខ្មែរ ឬ អាណាព្យាបាលពន្យល់ណែនាំដល់កូនចៅឲ្យបានដឹងបានស្គាល់ និងចូលរួមរក្សាប្រពៃណី វប្បធម៌ខ្មែរនោះឡើយ" ។ កញ្ញា សុខគន្ធា បានបន្តទៀតថា"ពេលចូលឆ្នាំយួន ក្រសួងអប់រំ និងបណ្ដុះបណ្ដាលបានប្រកាសជាសកល អនុញ្ញាតឲ្យនិស្សិតបានសម្រាកមួយសប្ដាហ៍ ដើម្បីចូលរួមស្វាគមន៍ថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិគេ តែនៅពេលដែលថ្ងៃចូលឆ្នាំប្រពៃណីខ្មែរបានឈានចូលមកដល់ ទាំងក្រសួងអប់រំ និងនាយកសាលាបែរជាធ្វើព្រងើយកន្តើយទៅវិញ ។ មិនតែប៉ុណ្ណោះ បែរជាបង្ខំឲ្យនិស្សិតទាំងអស់ហ្វឹកហាត់យោធា ពីរបៀបក្រាប លូន បាញ់ ធ្វើសង្គ្រាមទៅវិញនៅក្នុងកំឡុងថ្ងៃបុណ្យចូលឆ្នាំថ្មី ដោយគ្រូបង្រៀនបានប្រាប់ថានេះជាវិញ្ញាសាមួយសម្រាប់យកពិន្ទុឡើងថ្នាក់ បើមករៀន គឺជាប់ តែបើអត់មកទេ គឺធ្លាក់" ។

រីឯនិស្សិត ចៅ សុភាព ដែលមានអាយុប្រមាណ ២៥ ឆ្នាំ សព្វថ្ងៃជានិស្សិតឆ្នាំទី ៤ ជំនាញប្រវត្តិសាស្ត្រ ។ សុភាពបានផ្ដល់ព័ត៌មានដល់អ្នកយកព័ត៌មានយើងខ្ញុំដូច្នេះថា "យួនគេមិនដែលស្រឡាញ់ខ្មែរ និងជួយរក្សានូវប្រពៃណីទំនៀមទំលាប់ខ្មែរនោះទេ ថ្វីត្បិតតែពួកគេនិយាយថាសាមគ្គី ៗ ក៏ពិតមែន តែក្នុងចិត្តរបស់ពួកថ្នាក់ដឹកនាំ ពោរពេញទៅដោយការរើសអើង ដូចដែលសុភាសិតខ្មែរបានពោលថា "ក្ដៅស៊ីរាក់ ត្រជាក់ស៊ីជ្រៅ"ដូច្នោះដែរ ។ យួនផ្អែមនឹងខ្មែរ គឺគេចង់អូសទាញខ្មែរឲ្យធ្លាក់ទឹកតែប៉ុណ្ណោះ ។ ករណីជាក់ស្ដែងគឺរូបខ្ញុំផ្ទាល់ ក្នុងម៉ោងរៀនប្រវត្តិសាស្ត្រម្ដង ៗ ត្រូវយួនបញ្ចូលមនោគមន៍វិជ្ជាស្ទើរឆ្កួតទៅហើយ ចំណុចណាក៏ថាខ្មែរយើងខ្សោយ ហើយយួនជាអ្នកមានគុណចំពោះខ្មែរជានិច្ច តែផ្ទុយទៅវិញយួនទេ ដែលជាអ្នករមឹលគុណ និងព្យាយាមលុបបំបាត់ពូជខ្មែរឲ្យសូន្យលើទឹកដីកំណើតរបស់ខ្លួនតែម្ដង សំខាន់គឺប្រពៃណីវប្បធម៌ខ្មែរ ដោយពាក្យចាស់តែងពោលថា "វប្បធម៌រលត់ជាតិរលាយ វប្បធម៌ពណ្ណរាយជាតិថ្កើងថ្កាន"។ បើវប្បធម៌ និងប្រពៃណីខ្មែរបាត់បង់ខ្មែរក្រោមក៏ត្រូវបាត់បង់ដែរ ។ ដូច្នេះសូមនិស្សិតទាំងអស់កុំចាញ់បោក និងស្ដាប់នូវការញុះញង់របស់យួនឲ្យសោះ" ។

សូមបញ្ជាក់ផងដែរថា ក្រោយពីត្រូវបាននាយកសាលាគំរាមកំហែង មិនឲ្យនិស្សិតបានឈប់សម្រាកដើម្បីចូលរួមថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ សព្វថ្ងៃនិស្សិតមហាវិទ្យាល័យខេត្តអានយ៉ាងកំពុងត្រូវបង្ខំឲ្យហ្វឹកហាត់យោធាដែលហាក់បីដូចជាប្រុងប្រៀបខ្លួនធ្វើសង្គ្រាម និងនរណាអ៊ីចឹង ៕

សោភ័ណ

# សម្ព័ន្ធសមណនិស្សិត-និស្សិតខ្មែរកម្ពុជាក្រោមប្រារព្ធពិធីអបអរបុណ្យចូលឆ្នាំថ្មី

សម្ព័ន្ធសមណនិស្សិត-និស្សិតខ្មែរកម្ពុជាក្រោម បាន ប្រារព្ធពិធីជំនួបសមណនិស្សិត និស្សិត និងពុទ្ធបរិស័ទ នៅវត្ត សាមគ្គីរង្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានី ភ្នំពេញ កាលពីថ្ងៃទី ៨ ខែមេសា កន្លងទៅ ដើម្បីអបអរសាទរ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំច អដ្ឋស័ក ព.ស ២៥៥០ គ.ស. ២០០៦ យ៉ាងអធិកអធមបំផុត ហើយនេះជាចំណាប់ អារម្មណ៍របស់សមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម ដែល ថ្លែងដោយកញ្ញា ឈួន សុចិន្តា៖

ឆ្លៀតក្នុងឱកាសដ៏ប្រពៃនៃជំនួបសមណនិស្សិត និស្សិត និងពុទ្ធបរិស័ទខ្មែរកម្ពុជាក្រោម ដែលរៀបចំឡើង ដោយសម្ព័ន្ធសមណនិស្សិត-និស្សិតខ្មែរកម្ពុជាក្រោម ដើម្បីអប អរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខាងមុខនេះ ។ នាងខ្ញុំតាងនាម ឲ្យនិស្សិតខ្មែរកម្ពុជាក្រោមទាំងអស់ ដែលកំពុងរស់នៅឯកម្ពុជា ក្រោម នៅព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានៅបណ្តាប្រទេស លើពិភពលោក ។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី បងប្អូននិស្សិត ទាំងអស់ដែលបានអនុញ្ញាតឲ្យនាងខ្ញុំបានឡើងមកធ្វើចំណាប់ អារម្មណ៍ពីសកម្មភាព ទិដ្ឋភាពនៃការសិក្សា និងរាល់ការចូល រួមការងារសង្គមរបស់សមណនិស្សិត-និស្សិតខ្មែរកម្ពុជាក្រោម កន្លងមក និងកំពុងបន្តរួមចំណែកនាពេលអនាគត ។ ជា ពិសេសចំពោះការផ្តើមគំនិតឲ្យមានថ្ងៃនេះឡើងរបស់សម្ព័ន្ធ សមណនិស្សិត-និស្សិតខ្មែរកម្ពុជាក្រោមយើង ក្រោមការជួយ ជ្រោមជ្រែងរបស់អង្គការសមាគមខ្មែរកម្ពុជាក្រោមក្នុង និងក្រៅ ប្រទេស ពុទ្ធបរិស័ទគ្រប់ទិសទី ។ ចាប់តាំងពីនាងខ្ញុំព្រះករុណា យើងខ្ញុំទាំងអស់គ្នា បានព្រមព្រៀងគ្នាចូលរួមជាមួយសម្ព័ន្ធ សមណនិស្សិត-និស្សិតខ្មែរកម្ពុជាក្រោមមក ញុំាងយើងខ្ញុំដែល ជាសមណនិស្សិត-និស្សិតខ្មែរក្រោមគ្រប់រូប ដែលឃ្លាតឆ្ងាយពី មាតុភូមិគ្មានទីពឹងនោះ មានបង្អែកដ៏រឹងមាំ ព្រមទាំងបានស្គាល់ និងយល់ពីតម្លៃនៃការសាមគ្គី និងឯកភាពគ្នាជាធ្លុងមួយ ក្នុង ឋានៈយើងជាជនរួមលោហិតតែមួយនោះ ។ ការជួបជុំគ្នាថ្ងៃ នេះ គឺជាឱកាសបញ្ជាក់ឲ្យជនរួមជាតិ អន្តរជាតិ ដឹងថាសមណ និស្សិត-និស្សិតខ្មែរកម្ពុជាក្រោម ដែលកំពុងរស់នៅក្រោមការ ដឹកនាំរបស់សម្ព័ន្ធសមណនិស្សិត-និស្សិតខ្មែរកម្ពុជាក្រោមនៅ ទូទាំងពិភពលោក បាននិងកំពុងចាប់ដៃគ្នាជាធ្លុងមួយបង្កើត ជាមហាគ្រួសារ ដែលគ្មានសត្រូវណាអាចបំបែកបំបាក់បាន ឡើយ ។



គណៈអធិបតីក្នុងពិធីជំនួបសម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម

ព្រះតេជគុណ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងមិត្តនិស្សិតជាទីគោរព !

ក្នុងឱកាសជំនួបដ៏មានន័យនេះ តាងនាមឲ្យនិស្សិត ខ្មែរកម្ពុជាក្រោមទាំងអស់ នាងខ្ញុំសូមបង្ហាញនូវទស្សនៈរបស់ និស្សិតយើង ដែលប្រមូលបានពីការសិក្សាប្រវត្តិសាស្ត្រ ពីគំរូវីរ ភាពរបស់បុព្វបុរសស្នេហាជាតិនៃយើង និងរៀមច្បងបាន បន្សល់ទុកមក និងតាមរយៈការចូលរួមស្ទើរគ្រប់កិច្ចការសង្គម ក្នុងរយៈកាលកន្លងមក ឃើញថាគ្រប់កិច្ចការទាំងឡាយដែល មានការប្រមូលផ្តុំជាប្រព័ន្ធក្នុងរូបភាពតូចក្តីធំក្តី អាចសម្រេច ជោគជ័យបាន ត្រូវតែប្រតិបត្តិស្របតាមកត្តារបស់វា រួមមាន ធនធានមនុស្ស សមត្ថភាព បទពិសោធ សាមគ្គី ។ល។ ទោះ ជាយ៉ាងណាក៏ដោយ ការសាមគ្គី គឺជាកត្តាចម្បងមួយ ដែលធ្វើ ឲ្យសង្គម ឬក្រុមនោះទទួលបានជោគជ័យ ។ ផ្ទុយទៅវិញ ការ បែកបាក់សាមគ្គី នាំមកនូវបរាជ័យយ៉ាងឆាប់រហ័សបំផុត ។

គណៈអធិបតីជាទីគោរព ភ្ញៀវកិត្តិយសជាទីរាប់អាន ! មកដល់ចំណុចនេះ យើងចង់ធ្វើការវិភាគឲ្យបានច្បាស់ថែម ទៀត លើវិបត្តិទាំងឡាយដែលសង្គមខ្មែរយើងត្រូវទទួលរងជា បន្តបន្ទាប់ ពីជំនាន់មួយទៅជំនាន់មួយ ក្នុងនោះយើងឃើញថា គ្រប់គ្រាដែលខ្មែរត្រូវបរាជ័យ ខ្មែរតែងតែត្រូវគេបំបែកឲ្យបែក បាក់ជាច្រើនក្រុម ហើយក្រុមទាំងនោះក៏ប្រឈមមុខដាក់គ្នា រហូតដល់ស៊ីសាច់ហុតឈាមគ្នានៅដំណាក់កាលចុងក្រោយ ។ ជីវិតរាស្ត្រខ្មែរត្រូវស្លាប់ដូចសត្វ ឈាមហូរស្ទើរក្លាយជាស្ទឹង ទឹកដីខ្មែរដ៏ល្វឹងល្វើយត្រូវសត្រូវកាត់យកទៅសល់យ៉ាងតូច ចង្អៀត រាស្ត្រខ្មែរប្រែក្លាយពីម្ចាស់ប្រទេស ទៅជាទាសកររបស់

អ្នកឈ្លានពានទៅវិញ ។ ទន្ទឹមនឹងនេះ យើងក៏ត្រូវដឹងដែរថា មូលហេតុអ្វីដែលចេះតែធ្វើឲ្យខ្មែរបែកបាក់សាមគ្គីនោះ ?

ចំណុចនេះ យើងបានវិភាគឃើញថា មូលហេតុរបស់វា គឺយើងខ្វះកត្តាជោគជ័យគ្រប់គ្រាន់ ក្នុងនោះមានដូចជា ធនធានមនុស្ស សមត្ថភាព បទពិសោធ និងសាមគ្គីភាព ។

រាល់ទង្វើទាំងអស់នេះ បានធ្វើឲ្យយើងទាំងអស់គ្នា ដែលជាសមណនិស្សិត-និស្សិតខ្មែរកម្ពុជាក្រោម ទោះឃ្លាតឆ្ងាយពីភូមិកំណើតរស់នៅដោយជីវភាពខ្វះខាតក្តី យើងនៅតែខិតខំតស៊ូរៀនសូត្រ និងចូលរួមបម្រើរាល់សេចក្តីត្រូវការនៃសង្គមខ្មែរកម្ពុជាក្រោមទាំងកំពុងសិក្សា ពីព្រោះការប្រឹងប្រែងទាំងប៉ុន្មានរបស់យើង ថ្ងៃនេះគឺជាការត្រៀមលក្ខណៈទទួលខុសត្រូវសម្រាប់បន្តវេនអនុវត្តនូវគំរូដ៏ប្រពៃរបស់បុព្វបុរសយើង ក្នុងការការពារនូវប្រពៃណី ទំនៀមទំលាប់ វប្បធម៌ អារ្យធម៌ ធ្វើឲ្យយើងអាចអាន សរសេរ និយាយសូរសំនៀងត្រូវតាមអក្សរសាស្រ្ត ភាសា និងស្គាល់ច្បាស់នូវអត្តសញ្ញាណរបស់ខ្លួនរហូតដល់ពេលនេះ ។ ជាមួយនឹងពេលវេលាដ៏វែងអន្លាយ និងពោរពេញទៅដោយឧបស័គ្គ គ្រោះថ្នាក់ដ៏សែនមហន្តរាយក៏ដោយ ក្រៅពីនេះសមណនិស្សិត-និស្សិតខ្មែរកម្ពុជាក្រោម មានកាតព្វកិច្ចឆ្លើយតបនូវសំណូមពរ នូវឧត្តមគតិស្នេហាជាតិរបស់សប្បុរសជនម្ចាស់ជំនួយទាំងអស់ ដែលបានផ្តល់អាហារូបករណ៍ និងការឧបត្ថម្ភផ្សេង ៗ សម្រាប់ជួយដល់សមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោមនៅថ្ងៃអនាគត ។ ដូច្នេះ យើងខ្ញុំមិនអាចបំភ្លេចបានឡើយនូវគុណូបការៈដ៏ខ្ពង់ខ្ពស់របស់ព្រះតេជគុណ សប្បុរសជនក្នុង និងក្រៅប្រទេស និងអង្គការសមាគមខ្មែរនានាដែលបានផ្តល់ថវិកា និងកម្លាំងចិត្តដល់យើងខ្ញុំក្នុងការសិក្សារៀនសូត្រ និងបន្តចូលរួមជាមួយសម្ព័ន្ធសមណនិស្សិតនិស្សិតខ្មែរកម្ពុជាក្រោម ដើម្បីបម្រើផលប្រយោជន៍ប្រជាជាតិខ្មែរកម្ពុជាក្រោមដ៏ជាទីស្នេហានៃយើង ។ ក្នុងនាមជាកុលបុត្រកុលធីតាខ្មែរកម្ពុជាក្រោមជំនាន់ក្រោយ យើងមិនអាចបំភ្លេចបានឡើយនូវការតស៊ូដ៏លំបាកវេទនារបស់បុព្វបុរសយើង ដើម្បីថែរក្សាពូជសាសន៍ អារ្យធម៌ វប្បធម៌ សាសនា និងប្រពៃណីទំនៀមទំលាប់ខ្មែរកម្ពុជាក្រោមឲ្យបានគង់វង្សស្ថិតស្ថេររហូតដល់សព្វថ្ងៃនេះ ។

យើងខ្ញុំសូមតម្កល់ទុកនូវការចូលរួមឧបត្ថម្ភសម្រាប់បណ្តុះបណ្តាលធនធានមនុស្សដ៏ថ្លៃថ្លារបស់បងប្អូនខ្មែរកម្ពុជាក្រោមដែលនៅក្នុង និងក្រៅប្រទេសជាការបរិច្ចាគដ៏ខ្ពង់ខ្ពស់ដើម្បីបុព្វហេតុជាតិ សាសនា មាតុភូមិ និងការទប់ស្កាត់នូវការបាត់បង់ពូជសាសន៍ខ្មែរកម្ពុជាក្រោម ។ សំខាន់ជាងនេះ គឺរួមចំណែកក្នុងការជួយជំរុញឲ្យកុលបុត្រកុលធីតាខ្មែរកម្ពុជាក្រោម



ទិដ្ឋភាពនៃការចូលរួមរបស់សមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម

មានលទ្ធភាពគ្រប់គ្រាន់ ក្នុងការទាមទារសិទ្ធិជាម្ចាស់ទឹកដីដូនតាខ្លួន សិទ្ធិរស់រានមានជីវិត សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ដូចជាពូជសាសន៍មួយចំនួននៅលើពិភពលោក ដែលថ្មី ៗ នេះបានសុំសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង និងសិទ្ធិជាម្ចាស់ទឹកដីផងដែរនោះ ។

ការជួបជុំថ្ងៃនេះ ពិតជាមានន័យធំធេងណាស់ចំពោះយើងទាំងអស់គ្នា ហើយក៏ជាឱកាសមួយ ដែលយើងបានបង្ហាញនូវសុឆន្ទៈពិតប្រាកដ វិសាលភាពដ៏ធំធេងនៃការខិតខំបណ្តុះបណ្តាលធនធានមនុស្ស សូមសម្តែងនូវកតញ្ញូតាធម៌ចំពោះម្ចាស់អំណោយគ្រប់រូប ដែលមានវត្តមាននៅទីនេះ និងការដឹងគុណចំពោះម្ចាស់អំណោយមួយចំនួនទៀត តាមរយៈវេទិកានេះ ក៏ដូចជាតាមរយៈការសែតវីដេអូ ដែលមានមនុស្សកុះករនៅទីនេះជាអ្នកដឹងឮផងដែរ ។

ជាអនុសាសន៍សម្រាប់សមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោមតាមរយៈអង្គពិធីនេះ នាងខ្ញុំសូមអំពាវនាវដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អង្គការ សមាគម សប្បុរសជន ដែលរស់នៅក្នុង និងក្រៅប្រទេស មេត្តាជួយផ្តល់អាហារូបករណ៍ដល់សម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោមជាបន្តទៀត ដើម្បីការអភិវឌ្ឍន៍នៃសង្គមខ្មែរកម្ពុជាក្រោមយើង ។

អវសាននៃចំណាប់អារម្មណ៍ នាងខ្ញុំសូមថ្លែងនូវអំណរគុណជាថ្មីម្តងទៀត និងសូមប្រគេន ជូនពរ ព្រះតេជគុណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយស និងនិស្សិតទាំងអស់ បានសម្រេចនូវជោគជ័យគ្រប់ភារកិច្ចនាឆ្នាំថ្មី និងបានប្រកបដោយពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ៕

VOKK

# រកឃើញឧបករណ៍ថតសំឡេង

## ក្នុងបន្ទប់រៀននៅវត្តស្រឡូង



វត្តស្រឡូង ស្ថិតក្នុងឃុំលឿងភី ស្រុកស្វាយទង ខេត្តមាត់ជ្រូក កម្ពុជាក្រោម បានបើកវគ្គសិក្សាផ្នែកពុទ្ធិកសិក្សាតាំងពីដើមខែឧសភា ឆ្នាំ ២០០៥ កន្លងទៅនេះ ដែលមានការចូលរួមជ្រោមជ្រែងពីសំណាក់គ្រូអាចារ្យមកពីបណ្ដាវត្តជាច្រើន និងមានសមណសិស្សប្រមាណ៣៨ អង្គ ដែលនិមន្តមកពីក្នុងស្រុក និងបណ្ដាខេត្តនានា ។ រហូតមកដល់ខែកញ្ញា ឆ្នាំ ២០០៥ នៅក្នុងបន្ទប់រៀននៃពុទ្ធិកសិក្សា ព្រះចៅអធិការវត្តព្រះនាម ស៊ឺង ហ៊ី រកឃើញឧបករណ៍តាមដាន និងថតសំឡេងប្រមាណជាង ៧ គ្រឿង ដែលអាជ្ញាធរយួនបានដាក់ភ្ជាប់ទៅនឹងជញ្ជាំង និងក្នុងថតតុ ដើម្បីថតសំឡេង និង តាមដានរាល់សកម្មភាពបង្រៀនរបស់គ្រូអាចារ្យ ។

បើតាមប្រភពព័ត៌មានពីគ្រូអាចារ្យ ដែលបង្រៀនថ្នាក់ពុទ្ធិកសិក្សានៅវត្តស្រឡូង បានឲ្យដឹងថា វត្តស្រឡូងត្រូវបានអនុញ្ញាតឲ្យបើកសាលាពុទ្ធិកសិក្សា កាលពីខែឧសភា ឆ្នាំ ២០០៥ ដោយមានការចូលរួមពីសំណាក់គ្រូអាចារ្យជាច្រើនធ្វើដំណើរមកពីវត្តជីក្អែង ក្នុងនោះរួមមានលោកគ្រូ ចៅ សារិទ្ធ និងលោកគ្រូ ចៅ សំអឿន ជាដើម ។ ដោយសារសកម្មភាពបំផុសបំផុលរបស់គ្រូទាំងពីររូបខាងលើនេះ រហូតមកដល់ខែកញ្ញា ឆ្នាំដដែល អាជ្ញាធរយួនបានរឹតបន្តឹងក្នុងការតាមដាននូវកម្មវិធីសិក្សាថ្នាក់ពុទ្ធិកសិក្សានេះ ។ បន្ទាប់មកព្រះចៅអធិការវត្ត ព្រះនាម ស៊ឺង ហ៊ី ដែលជានាយកសាលាប្រចាំវត្ត តែងត្រូវបានអាជ្ញាធរយួនកោះហៅទៅប្រជុំ ដើម្បីណែនាំពីបញ្ហាអប់រំថ្នាក់ពុទ្ធិកសិក្សាជាញឹកញាប់ ។

ដោយសេចក្ដីស្រេកឃ្លាន នូវចំណេះដឹងអក្សរសាស្ត្រខ្មែរ និងប្រវត្តិសាស្ត្រដ៏ជូរចត់នោះ បណ្ដាលឲ្យសមណសិស្សចូលរួមយ៉ាងកុះករ ។ រីឯលោកគ្រូអាចារ្យ ចៅ សំអឿន និងលោកគ្រូ ចៅ សារិទ្ធ ដែលមានដើមកំណើតនៅភូមិជីក្អែង បានព្យាយាមរួមចំណែកក្នុងការបង្ហាត់បង្រៀន ដោយមិនគិតពីភាពនឿយហត់ឡើយ ។ មិនតែប៉ុណ្ណោះ លោកគ្រូទាំងពីរតែងបានពន្យល់ណែនាំដល់សមណសិស្សទាំងឡាយ ឲ្យបានដឹងពីប្រវត្តិសាស្ត្រខ្មែរក្រោម និងទុក្ខខ្មែរក្រោម ក្រោមរបបកុម្មុយនិស្តយួន ទាំងនេះហើយទើបបណ្ដាលឲ្យអាជ្ញាធរថ្នាក់ខេត្តកោះហៅលោកទៅអប់រំជាញយ ៗ ។ មកដល់ចុងខែកញ្ញា ស្រាប់តែព្រះចៅអធិការវត្ត បានរកឃើញប្រដាប់តាមដាន និងថតសំឡេង នូវសកម្មភាពបង្រៀនរបស់គ្រូនៅក្នុងបន្ទប់សិក្សា ។

លោក ចៅ សារិទ្ធ គ្រូអាចារ្យផ្នែកវិញ្ញាសាសរសេរតាមអាន អាយុប្រមាណ ៣០ ឆ្នាំ សព្វថ្ងៃបានរត់ភៀសខ្លួនទៅដល់ព្រះរាជាណាចក្រកម្ពុជា បានប្រាប់អ្នកយកព័ត៌មានថា "ការដាក់ប្រដាប់តាមដានសំឡេងនេះ មិនមែនទើបតែកើតមានថ្មី ៗ នេះទេ ហើយក៏មិនមែនជាលើកទី ១ ដែរ នេះគ្រាន់តែគ្រូបង្រៀនមិនចង់ឲ្យមានរឿងតែប៉ុណ្ណោះ ព្រោះខ្លាចយួនគេបិទសាលារៀន តែបើយោងតាមសភាពការណ៍បែបនេះ សឲ្យឃើញថា បើទោះបីជាត្រូវយួនអនុញ្ញាតឲ្យបើកសាលាបាលីក៏ដោយ ក៏រដ្ឋអំណាចយួននៅតែតាមដាន និងមិនទុកចិត្តចំពោះការអប់រំនេះដែរ ។ ជាក់ស្ដែងពួកគេបានដាក់ប្រដាប់តាមដានសកម្មភាព និងថតសំឡេងនៅក្នុងបន្ទប់រៀនតែម្ដង ដោយគេខ្លាចគ្រូបង្រៀនរំលឹកឡើងវិញនូវសោកនាដកម្មដ៏សែនឈឺចាប់ គឺយួនសម្លាប់ខ្មែរ ល្បិចយួនជន្លៀសខ្មែរខេត្តមាត់ជ្រូក និងប្រវត្តិកំពប់តែអុងជាដើម ប្រាប់ដល់សមណសិស្ស" ។

ទាក់ទិននឹងបញ្ហានេះដែរ អ្នកយកព័ត៌មានយើងខ្ញុំមិនអាចធ្វើការទំនាក់ទំនង សុំការពន្យល់ពីព្រះចៅអធិការវត្តបានឡើយ ។ តែទោះជាយ៉ាងណាក៏ដោយ មតិរបស់ប្រជាពលរដ្ឋខ្មែរ និងពុទ្ធបរិស័ទចំណុះជើងវត្ត បានសម្ដែងការមិនពេញចិត្តចំពោះទង្វើនេះឡើយ ដោយពួកគាត់យល់ថា នេះជាការគាបសង្កត់បំពានសិទ្ធិសេរីភាព សិទ្ធិទទួលព័ត៌មាន ។ រីឯសមណសិស្សគ្រប់ព្រះអង្គ គ្រាន់តែមានសង្ឃដីកា "បើបានរៀនប្រវត្តិ-សាស្ត្ររបស់យើង គឺជាការល្អខ្លាំងណាស់" ៕ សោ ភ័ណ

# រឿងកំពប់តែអុង

អត្ថបទកំណាព្យនេះ ត្រូវបានរក្សាទុកអក្ខរាវិរុទ្ធ
តាមច្បាប់ដើមទាំងស្រុង

## សាស្ត្រាវត្តក្រូច – រៀបរៀងដោយសាស្ត្រាចារ្យ ឃឹន សុខ



ឃ្មួនយកក្បាលខ្មែរធ្វើជាមុំចង្ក្រានកល់ដាំតែអុង

៨៣៩-ឯអស់រាស្ត្រទាំងឡាយ រត់ប្រញាយ
ទៅទីទៃ ទៅរកពួនក្នុងព្រៃ
ពឹងប្រាស្រ័យកម្លាំងកាយ ។
៨៤០-កំពង់សៀមដើងព្រៃ សឹងភិតភ័យពុំ
សប្បាយ រៀងរាល់ទាល់បារាយណ៍
កំពង់ស្វាយដែលដូចគ្នា ។
៨៤១-រីឯខេត្តបារាយណ៍ រត់ប្រញាយឡើង
ចំការ ព្រៃធំជុំជិតគ្នា
ខ្លះនៅនាក្បាលទឹកហុង្ស ។
៨៤២-មានកាលថ្ងៃមួយនោះ
ក្មេងវាដោះមាត់កំពង់ នឹងដងទឹកក្បាលហុង្ស
ព្ញុយុង ៗ ថាស្គរទ័ព ។
៨៤៣-ភ្ញាក់ផ្អើលឡើងឆោឡោ
រត់រថៅភ័យស្ទើរស្លាប់ កូនចៅហៅប្រញាប់
ថានែទ័ពគេមកដល់ហើយ ។
៨៤៤-ខ្លះស៊ីបាយនឹងមាត់ ខ្លះទើបញាត់បាយនៅ
ឡើយ ខ្លះបានស៊ីរួចហើយ ដោយដំណើរនោះទីទៃ ។
៨៤៥-លុះព្ញុថាទ័ពដល់ រត់រចល់ភាំងភិតភ័យ
រកហៅគ្នាទីទៃ ពាសពេញព្រៃព្រាត់កូនចៅ ។
៨៤៦-ខ្លះបានជួបជុំគ្នា ពុំយូរយារែកទូលទៅ
ខ្លះចាំជុំកូនចៅ ស្រេចទើបទៅតាមជាក្រោយ ។
៨៤៧-ខ្លះខ្លួនទាល់ក្រៃក្រៃ មានកូនខ្ចីប្តីឯងឲ្យ
ប្រពន្ធបីកូនក្រោយ ទូលបង្វិចតិចទេហោង ។
៨៤៨-ឯប្តីរែកអង្ករ ឆ្នាំងសម្លរឆ្នាំងបាយផង
រែកធ្ងន់ពន់កន្លង ទន់ទាំងខ្នងទ្រាំគ្រោះគ្រា ។
៨៤៩-ខ្លះមានកូនតូចស្ទើរ នឹងបណ្តើរពុំទាន់ឈ្មោះ
ដល់លើកញ្ជើចុះ លើករែកស្មោះចចេញទៅ ។
៨៥០-ឯកូនកុមារនោះ រែកដូចនោះអររថៅរៅ
ហេតុក្មេងពុំដឹងជ្រៅ ថាជាទៅលេងសប្បាយ ។
៨៥១-ឯអង្គអាពុកធ្ងន់ ទ្រាំត្រិនត្រុនទ្រូងស្ទើធ្លាយ
ខំរែកបែកញើសខ្លាយ ពោះតែស្តាយសាច់សង្ឃា ។
៨៥២-ឯកូនគិតពុំជ្រៅ ពុំដឹងឪធ្ងន់ឡើយណា
ដាក់អង្រែកពីលើស្មា កូននោះណាយំទធាក់ ។
៨៥៣-ថាចង់ជិះកញ្ជើ ឲ្យរែកដើរកុំឲ្យដាក់
អាពុកខឹងកន្ទ្រាក់ ដាវលើកយាថាអាឯង ។
៨៥៤-អញកាប់ចោលបង្វៀត ទៅឲ្យត្មាតវាប្រជែង
កូនខូចដូច្នេះឯង តើនឹងលេងទុកវាថ្វី ។
៨៥៥-កូនយល់អាពុកខឹង បាត់មាត់ឈឹងស្ងៀមនៅខ្មី
ពុំយំពុំស្រដី ថាអ្វី ៗ ឡើយស្ងៀមសោះ ។
៨៥៦-ឯអស់គ្រួរនោះនៃ ដើរដោយព្រៃសំសាន្តគ្រោះ
វង្វេងវិលវុលចុះ មកជំពោះគិតពីយប់។
៨៥៧-ប្រពន្ធប្រាប់ទៅប្តី ថានែវ៉ីដែលយើងឈប់

ដាក់គិតកាលពីយប់ នោះឯងមិញអញចាំដាក់ ។
៨៥៨-វង្វេងវុលចុះឡើង អន់អស់ជើងហើយឈប់
ដាក់ គ្នាច្រើនជ្រួលគ្រឹកគ្រាក់ ឈប់ដល់ដាក់ដុះជួបជុំ។
៨៥៩-ស្រេចហើយបណ្ដឹងគ្នា សាកសួរសាគិតជុំនំ
នរណាពុស្ដរធំ ថាទ័ពជុំដល់ដូច្នេះ ។
៨៦០-ដន្លឹងសាកសួរសព្វ អស់គ្រួរគ្រប់ទៅជំពោះ
លើក្មេងដែលវាគោះ បំពង់នោះអស់សង្ស័យ ។
៨៦១-សើចសួក្អាកក្អាយ សុកសប្បាយឥតទុកភ័យ ធ្វើ
ស្របនៅទីទៃ តាំងពីថ្ងៃនេះឥតហ្មង ។
៨៦២-ឈប់នៅនាទីនោះ នឹងដូច្នេះហើយកេនកង
ឧកញ្ញាព្រហ្មជាស្នង គិតកេនកងវាស្ត្រទីទៃ ។
៨៦៣-ប្រពន្ធគាត់ឈ្មោះម៉ា1 នឹតនៅនាភូមិទ្រាលនៃ
មានព្រហ្មមួយដទៃ ធ្វើជាងារក្រឡាពាស ។
៨៦៤-តែងនៅជួបជុំគ្នា គិតរាជការរក្សាវាស្ត្រ
ព្រហ្មជាក្រឡាពាស ប្រពន្ធពីរឥតឆ្គង ។
៨៦៥-ប្រពន្ធមួយឈ្មោះម៉ា មួយឈ្មោះជាតូចវិញ
ហោង គាត់សង់ផ្ទះនៅផង ភូមិទន្លេវាលវិញដាក់ ។
៨៦៦-ឧកញ្ញាព្រហ្មទាំងពីរ នៅស្និទ្ធស្នេហ៍ថែវាស្ត្ររាក្យ
សត្រូវគ្រប់ជាងដាក់ ពឹងពំនាក់អស់អង្គប្រាណ ។
៨៦៧-រវាតរវាំងគ្រប់ ផ្លូវសុះសព្វសឹងកដាន
ប្រយ័ត្នក្រែងមោះមាន សិកសត្រូវទៅដល់គ្រួរ ។
៨៦៨-តែងទៅមកសព្វថ្ងៃ ពួនពឹងព្រៃគ្រុបត្បួរ
តែងទៅមករកសួរ សៀមផាត់គ្រួឬជាទេ ។
៨៦៩-មានខាវល្បាតបំរើ គិតចាត់ប្រើទៅសួរគេ
គ្រប់គ្រួរទាល់ទន្លេ នោះឯងប្រាប់គេវិញនៃ ។
៨៧០-ថាយើងឲ្យបំរើ ទៅសួរសើរដល់ជើងព្រៃ
ថាមានមេធំក្រៃ ឈ្មោះហៅថានគរាជ ។
៨៧១-ដំរីច្រើនធំៗ ភ្លេងរងំមកមិនខ្លាច
ឯពញ្ញានាគរាជ ពលគេច្រើនមួយហ្មឺនប្លាយ ។
៨៧២-គេដើរដល់ជើងព្រៃ ពីរបីថ្ងៃដល់បារាយ៍
គេផាត់គ្រួរពីនាយ យកមករអាយបានច្រើនណាស់ ។

៨៧៣-ខាវល្បាតបានដឹងហើយ
ពុំលង់ឡើយវិលរហ័ស ហេតុដឹងដំណឹងច្បាស់
ភិតភ័យណាស់ស្រូតម្នីម្នា ។
៨៧៤-មកដល់ឧកញ៉ាព្រហ្ម ប្រាប់ដោយដំណើររាជ
ការ គ្រួរផងភិតក្ដាត់ណា ប្រាមប្រាប់គ្នាឲ្យប្រញាប់ ។
៨៧៥-យកគ្រួរឡើងទៅទុក ព្រៃជិតស្ដុកស្ងៀមស្ងប់
ស្ងាត់ ប្រើប្រុសចេញរង្កាត់ ផ្លូវស្រឡៅនូវផ្លូវដារ ។
៨៧៦-ឯពញ្ញានគរាជ ឫទ្ធិអំណាចតូចសីហា
ឥតភ្លឹកសោះសារ ដល់ភូមិណាអុជអស់ឆេង ។
៨៧៧-អស់ល្បាតបានដើរដល់
ទ្រាលយុងយល់ឃើញតែផ្សែងស្រឡៅនោះឯង
អុជអស់ឆេងហើយហួសទៅ ។
៨៧៨-អស់ល្បាតខាងឯយើង
យល់អុជភ្លើងតាស្រឡៅ មិនហ៊ានដើរដោយផ្លូវ ព័ទ្ធ
ពួននៅដោយដងព្រៃ ។
៨៧៩-លឡប់លលិបឡ ដកដៃកចេញទីទៃ
មើលមកពីក្នុងព្រៃ ភ្នែកតែងរំពៃភ័យផងុក ។
៨៨០-ក្លះហានមានចិត្តនោះ ខំទម្លុះទៅដល់ព្រៃ
តាមដានដែលដើរទាក់ ទ័ពដំរីសេះរទេះ ។
៨៨១-ល្អិតល្អន់ល្អានជាឆ្លា ដោយមាត៌ាគិតរមរិះ
នឹងគ្នាថាទ័ពនេះ តើវាទៅនៅត្រឹមណា ។
៨៨២-អ្នកខ្លះឆ្លើយទៅវិញ ថាឯអញគិតទៅថា
ទ័ពយល់ជាវា បោះនៅនាភូមិប្រាសាទ ។
៨៨៣-បទអូរដ្សិតមានអូរក្បាលទឹក
ហូរគគិកស្មៅលាស់ស្អាត យល់ជានៅប្រសាទ
នោះពុំឃ្លាតនៅនោះឯង ។
៨៨៤-គិតស្រេចដើរព្រាងព្រៃ ភ្នែករំពៃគិតយល់ឆ្វេង
ច្រកល្អកស្រុកទីឯង តែងនិងដើរដឹងមុនស្រាប់ ។
៨៨៥-លុះលបទៅយង់យល់ អស់ពួកពលសៀមបោះ
ទ័ព ពលទីមីខ្នាន់ខ្នាប់ ដំរីសេះគោក្របី ។

(**នៅមានត**)

# អាថ៌កំបាំងនៅជាន់ទី ២ នៃប្រាង្គប្រាសាទអង្គរវត្ត

ប្រាសាទអង្គរវត្ត គឺជាសម្បត្តិវប្បធម៌ដ៏វិសេសវិសាលរបស់ជាតិសាសន៍ខ្មែរ ដែលបានកសាងឡើងនៅសម័យមហានគរដ៏រុងរឿង ក្នុងគោលបំណងឧទ្ទិសថ្វាយចំពោះព្រហ្មញ្ញ-សាសនា ហើយនៅសម័យក្រោយ ៗ មកទៀតទីនោះបានប្រែក្លាយជាវត្តអារាម សម្រាប់គោរពបូជាចំពោះព្រះពុទ្ធសាសនាវិញ ។ ប្រាសាទកំពូលប្រាំដែលមានស្រះបោក្ខរណីព័ទ្ធជុំវិញមានទឹកថ្លាឈ្វេងមើលឃើញឆ្លុះបាតដី ហើយសំណង់ប្រាសាទមានក្បូរក្បាច់រចនាល្អឆើតឆាយទឹកដៃខ្ពស់រស់រវើកបង្ហាញពីការរីកចម្រើនផ្នែកវប្បធម៌សិល្បៈ និងសំណង់ដល់កម្រិតកំពូល ព្រមទាំងបានទាក់ទាញភ្ញៀវទេសចរជាតិ អន្តរជាតិចម្រុះជាតិសាសន៍ ឲ្យទៅទស្សនាកំសាន្តយ៉ាងច្រើនសន្ធឹកសន្ធាប់លើសប្រាសាទនានាទូទាំងខេត្តសៀមរាប ។ ប៉ុន្តែអ្វីដែលចម្លែក ធ្វើឲ្យអារម្មណ៍អ្នកទេសចរមិនអាចភ្លេចទៅកំសាន្តនោះ គឺកន្លែងប្រាសាទគក់ទ្រូង ដែលពួកគេនាំគ្នាឈរផ្អែកខ្នងជាប់នឹងជញ្ជាំង ហើយក្តាប់ដៃគក់លើដើមទ្រូងមានសូរសម្លេងប្លែកពីធម្មតាខ្ទរពេញដើមទ្រូង បង្កើតជាចម្ងល់ជាប់មិនដាច់ ហើយទីនោះមានរឿងនិទានជាច្រើនខុសគ្នា តែបង្ហាញនូវអត្ថន័យតែមួយដែលទាក់ទងទៅនឹងប្រាសាទ ។

ប្រាសាទអង្គរវត្ត ស្ថិតនៅភូមិសាស្ត្រ ស្រុកសៀមរាប ចម្ងាយពីទីរួមខេត្តប្រមាណ ៧ គីឡូម៉ែត្រនៅភាគខាងជើងតាមបណ្តោយផ្លូវកូម៉ៃ ដែលកសាងក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២ នាសតវត្សរ៍ទី ១២ (១១១៣-១១៥០) ដើម្បីឧទ្ទិសថ្វាយចំពោះព្រះវិស្ណុ ក្នុងលទ្ធិព្រហ្មញ្ញសាសនា ។ សំណង់ប្រាសាទនេះមានរាងបួនជ្រុងទ្រវែង ដែលមានបណ្តោយ ១៥០០ ម៉ែត្រ គុណនឹងទទឹង ១២៧៣ ម៉ែត្រ និងផ្ទៃដីទំហំប្រមាណ ២០០ ហិកតា កំពូលប្រាង្គប្រាសាទកំពស់ ៦៥ ម៉ែត្រ កំពែងព័ទ្ធជុំវិញ និងគូទឹកថ្លាឆ្វេង ហើយឆ្លុះបាតដី ។ នៅខាងមុខប្រាសាទមានដើមឈើចោលម្លប់ត្រឈឹងត្រឈៃ មានបរិវេណធំទូលាយ ដែលមនុស្សនិយមទៅអង្គុយកំសាន្ត និងរូបគោពីរកំពុងឈរបង្អួតភ្ញៀវទេសចរ រីឯនៅចុងផ្លូវចូលមានគោរបុរៈប្រាង្គបីដែលផ្នែកខាងលើខូចខាតមួយចំនួនធំ ផ្លូវចូលមានរូបនាគអមបង្កាន់ដៃ ដោយផ្លូវចូលប្រវែង ៣៥០ ម៉ែត្រ និងទទឹង ៩ ម៉ែត្រ សង់កាត់ស្រះបោក្ខរណីដើម្បីឆ្លងចូលក្នុងបរិវេណប្រាសាទ ។ ពេលឆ្លងផុតខ្លោងទ្វារ គេសង្កេតឃើញមានវេទិកា បណ្ណាល័យនៅអមសងខាងផ្លូវមានស្រះទឹកពីរ មួយរីងស្ងួត និងមួយទៀតមានទឹកតិច ៗ អាចឆ្លុះឃើញរូបប្រាសាទ ហើយអ្នកទេសចរទៅឈរបង្អួតដាក់គ្នាដើម្បីថតរូបទុកជាអនុស្សាវរីយ៍ ព្រមទាំងមានទីលានកិត្តិយសសម្រាប់សម្តែងសិល្បៈឲ្យទស្សនិកជន និងព្រះមហាក្សត្រទស្សនាពេលមានកម្មវិធីម្តង ៗ ។ ប្រាសាទកំពូលប្រាំដ៏ល្អវិចិត្រនេះ ត្រូវបានអ្នកប្រាជ្ញជាតិ និងអន្តរជាតិបញ្ចេញទស្សនៈខុស ៗ គ្នា ខ្លះថាសង់ដើម្បីឧទ្ទិសថ្វាយចំពោះព្រះវិស្ណុពេលចូលទីវង្គត ដោយឲ្យព្រះនាមថា "ព្រះបរមវិស្ណុ" ខ្លះថាជាចេតីយ៍សម្រាប់បញ្ចុះព្រះធាតុព្រះបាទសូរ្យវរ្ម័នទី២ តាមទំនៀមទំលាប់ប្រពៃណីខ្មែរពីបុរាណ គេថា បើកប់ខ្មោច ឬតម្កល់ខ្មោចលើជើងថ្កសម្រាប់ធ្វើការបូជា (ឈាបនកិច្ច) គេនិយមដាក់ក្បាលបែរទៅទិសខាងលិច ពេលកប់សពក៏គេនិយមដាក់ក្បាលទៅទិសខាងលិចដែរ ដោយគេយកតាមដំណើររបស់ព្រះអាទិត្យពេលរះពីទិសខាងកើត ហើយលិចទៅវិញនៅទិសខាងលិច ។ ចំណែកក្នុងរឿងព្រេងនិទានប្រាសាទអង្គរវិញថា ប្រា-សាទនេះ ត្រូវបានព្រះឥន្ទ្រាធិរាជកសាងថ្វាយចំពោះព្រះកេតុ-មាលា ដែលជាព្រះរាជបុត្រ ដើម្បីគ្រងរាជសម្បត្តិនៅក្នុងប្រទេសកម្ពុជា ។ ប៉ុន្តែបើយើងពិនិត្យពីលក្ខណៈសំណង់ប្រា-សាទទាំង ៣ ជាន់ គឺជាន់ទី ១ រាងកាកបាទ មានរូបចម្លាក់ល្អឆើតឆាយ ត្រូវបានអ្នកទេសចរគយគន់មិនដាក់ភ្នែក ញញឹមពព្រាយសរសើរមិនដាច់ពីមាត់ ។ នៅជាន់ទី ២ មានទីលាន ៤ ដែលមានអាងទឹក និងជណ្តើរគ្រប់ទិស បណ្ណាល័យ ២ មានរូបចម្លាក់យ៉ាងច្រើន និងនៅជាន់ទី ៣ គឺជាកន្លែងរបស់ព្រះមហាក្សត្រ គ្រូអាចារ្យ មន្ត្រីថ្នាក់ខ្ពស់ ដែលមានកំពូលទាំងប្រាំខ្ពស់ត្រដែតត្រូវបានគេសន្មតថាភ្នំសុមេរុ ប្រៀបដូចឋានកៃលាស ។



ប្រាសាទអង្គរវត្តជាន់ទី ២ ជាផ្នែកមួយទាក់ទាញអ្នកទេសចរទៅគក់ទ្រូង

នៅបរិវេណប្រាសាទអង្គរវត្តជាន់ទី ២ មានសំណង់ប្លែក ៗ គឺនៅត្រង់ចំណុចកណ្តាល គេសង្កេតឃើញសំណង់ខ្វាត់ខ្វែង ហាក់ដូចជាកន្លែងសម្រាប់វាស់ស្ទង់អ្វីមួយអញ្ចឹង ហើយនៅក្បែរមាត់ទ្វារ គេសង្កេតឃើញមនុស្សម្នាចូលទៅឈរផ្អែកខ្នងនឹងជញ្ជាំង ហើយក្តាប់ដៃគក់ទ្រូង ដែលអ្នកផងនិយម

ហៅថា "ប្រាសាទគក់ទ្រូង" ។ ទីនេះត្រូវបានអ្នកស្រាវជ្រាវ ក៏ដូចជាចាស់ទុំមួយចំនួនមានចំណាប់អារម្មណ៍ប្លែក ៗ ពីគ្នាថា "ភ្នំសុមេរុ" អាចជាទីសម្រាប់ព្រះសង្ឃសម្ដែងព្រះធម៌ទេសនាក្នុងឱកាសមានបុណ្យទានម្ដង ៗ ហើយចំណុចកណ្ដាលខ្វែងជើងក្អែក គេមានរៀបចំជាកន្លែងសម្រាប់តម្កល់ព្រះធម៌នាសម័យនោះ ក៏ដូចជាសម័យក្រោយដែរ ។ នៅត្រង់រោងទងខាងត្បូង ជាកន្លែងសម្រាប់តម្កល់ព្រះរយព្រះពាន់ ហើយពេលគេដើរចេញពីបន្ទប់នេះ ឃើញមានបណ្ណាល័យពីរទៀតសម្រាប់ព្រះសង្ឃគង់នៅ ។ ចំណែកកន្លែងខ្វែងជើងក្អែកសម្រាប់ឧបាសក-ឧបាសិកាអង្គុយស្ដាប់ព្រះធម៌ទេសនា នៅពេលចប់សម័យនោះ គេប្រើគងជាសញ្ញាដើម្បីបញ្ចប់កម្មវិធី ។ មតិទី ២ ថា ខណៈពេលកំពុងសាងប្រាសាទនេះ ពួកមេជាងជាច្រើនមើលឃើញកំពូលប្រាសាទសង់លៀនខុសពីធម្មតា មានចម្ងល់មិនចេះចប់ ហើយជជែកដេញដោលរកហេតុផល ពេលព្រះពិស្ណុការធ្វើឲ្យគាត់ខឹងដោយគ្រាន់តែប្រាប់ថា យកអំបោះប្រាំពីរសរសៃទៅទាក់នឹងឃ្លោករួចគោះតម្រង់វានឹងត្រង់ ពួកមេជាងមិនជឿ ហើយនាំគ្នាតម្រង់មិនចេះត្រង់សោះ ។ ព្រះពិស្ណុការឃើញកូនចៅមិនចេះស្ដាប់តាមការណែនាំរបស់ខ្លួន ក៏ដើរចេញលែងនៅសាងសង់សំដៅទៅស្រុកចិនបាត់ទៅ ពេលធ្វើអស់ចិត្តហើយ ព្រះពិស្ណុការមិននៅផងក៏សុខចិត្តធ្វើតាមការណែនាំនោះស្រាប់តែកំពូលប្រាសាទវាត្រង់ ក៏នាំគ្នាស្វែងរកព្រះពិស្ណុ-ការ តែមិនឃើញ មានការស្ដាយស្រណោះនាំគ្នាទៅឈរគក់ទ្រូងត្រង់កន្លែងនេះឯង ។ ខ្លះថាខណៈពេលព្រះពិស្ណុការធ្វើព្រះខ័នយកទៅថ្វាយព្រះកេតុមាលា ហើយព្រះអង្គទតឃើញទំហំព្រះខ័នតូច ក៏មានសេចក្ដីក្រោធយ៉ាងខ្លាំង ព្រមទាំងធ្វើការស្ដីបន្ទោសព្រះវិស្ណុការទាំងគំរោះគំរើយ នៅចំពោះមុខពួកនាម៉ឺនសព្វមុខមន្ត្រីថា "ឯងលួចដែកយើងយកទៅប្រើជាប្រយោជន៍ផ្ទាល់ខ្លួនបានជាដែក ៣ ហាប ធ្វើព្រះខ័នឲ្យយើងបានតែតូចមួយប៉ុណ្ណោះ ។ ព្រះពិស្ណុការខឹងច្រលោតគោតគូងដែរ ហើយឆ្លើយថា "ខ្ញុំលែងនៅស្រុកខ្មែរទៀតហើយ នឹងត្រឡប់ទៅប្រទេសចិនវិញ" ។ ព្រះពិស្ណុការថាហើយ ក៏អូសមុខព្រះខ័នលើក្ដារ ពេលចេញផុតទៅគេឃើញក្ដារដាច់ជាពីរ ព្រះរាជាឃើញដូច្នេះក៏បង្គាប់ឲ្យគេទៅតាមយកព្រះខ័នថ្វាយវិញ ប៉ុន្តែព្រះពិស្ណុការពុំព្រម ក៏គ្រវែងព្រះខ័នចោលកណ្ដាលទឹកទន្លេ ហើយចុះសំពៅទៅស្រុកចិនបាត់ ។ ព្រះរាជានាម៉ឺនសព្វមុខមន្ត្រីបន្ទាប់ពីដឹងហេតុការណ៍មានការសោកស្ដាយព្រះខ័ន និងព្រះពិស្ណុការ នាំគ្នាគក់ទ្រូងត្រង់ប្រាសាទនោះឯង ។ មតិទី ៣ គេថាកន្លែងប្រាសាទគក់ទ្រូងនេះ កាលពីសម័យមុនមានរឿងនិទានតំណាលថា កូនស្ដេចពីរព្រះអង្គបានស្រឡាញ់គ្នាចិត្តមួយថ្លើមមួយតាំពីតូចក្រូចឆ្មារ ដោយសន្យាថានឹងរៀបការជាមួយគ្នាជាប្ដីប្រពន្ធនៅពេលពេញវ័យ ។ ប៉ុន្តែជាអកុសលនៅពេលអ្នកទាំងពីរធំឡើង ស្រាប់តែបុត្រីស្ដេចកើតជំងឺមិនអាចព្យាបាលបានក៏សោយទិវង្គតចោលសង្សារ ធ្វើឲ្យព្រះរាជបុត្រមានព្រះទ័យសោកស្ដាយចំពោះអនុស្សាវរីយ៍របស់ខ្លួន ដែលធ្លាប់បានសាងជាមួយព្រះនាងមិនអាចបំភ្លេចបាន ក៏ចូលទៅក្នុងបន្ទប់ប្រាសាទ ហើយទ្រង់ព្រះកន្សែងខ្លាំង គិតតែឈរគក់ទ្រូងមិនឈប់ឈរ ទើបទីនេះគេនាំគ្នាហៅថាប្រាសាទគក់ទ្រូងរហូតមក ។ រីឯមតិទី ៤ យល់ថាបានជាកន្លែងនេះ គេហៅប្រាសាទគក់ទ្រូង ហើយឮសម្លេងខ្ទរខុសធម្មតា ដោយសារតែខាងក្រោមនៃសំណង់នេះ មានគេកប់គងជាច្រើនជាកំណល់ដើម្បីឲ្យមានសំលេងប្លែក ហើយអ្នកផងទាំងឡាយនាំគ្នាទៅឈរគក់ទ្រូងនៅទីនោះមិនដែលខកខាននោះទេ ដោយឲ្យឈ្មោះទីនោះថាប្រាសាទគក់ទ្រូង ។ នៅពីក្រោមដំបូលខ្វែងជើងក្អែក គេសង្កេតឃើញចម្លាក់អប្សរា ទេវតា រូបឥសី នៅតាមជញ្ជាំងប្រាសាទ ព្រមទាំងរូបសំណាកមួយចំនួនទៀតផង ។

ប្រាសាទអង្គរវត្ត ដែលមានឈ្មោះល្បាញល្បីដោយសារតែមានក្បាច់រចនាល្អវិសេសវិសាល ប្រៀបបីដូចជាឋានសួគ៌ា ធ្វើឲ្យអ្នកទេសចរមួយចំនួនស្ទើរតែមិនជឿថា បុព្វបុរសខ្មែរជាអ្នកសាងឡើង បែរជាយល់ថា ព្រះពិស្ណុការចុះពីឋានលើកសាងទៅវិញ ។ ប្រាង្គប្រាសាទនោះ មិនត្រឹមតែជាសម្បត្តិមរតករបស់ជាតិសាសន៍ខ្មែរទេ ត្រូវបានពិភពលោកចាត់ទុកជាបេតិកភ័ណ្ឌរបស់មនុស្សជាតិថែមទៀត ។ អ្នកទេចរខ្លះចូលចិត្តទៅទស្សនាប្រាសាទនេះពេលថ្ងៃរៀបអស្តង្គតរហូតដល់ថ្ងៃរៀបលិចផុតចុងព្រៃ ឃើញពន្លឺនៃព្រះអាទិត្យពណ៌មាស និងពណ៌ប្រាក់ជះមកលើប្រាសាទក្រហមឆ្អិនឆ្អៅទៀត អ្នកខ្លះមានចំណង់ទៅមើលប្រាសាទនោះនៅពេលថ្ងៃជិតរះឃើញពន្លឺក្រហមផុសមួយដុំចេញពីផ្ទៃងងឹត រហូតដល់កំពូលប្រាសាទចោលស្រមោលទៅលើប្រាសាទក្នុងផ្ទៃទឹក ប្រៀបបីដូចជាឋានសួគ៌ា ខ្លះទៀតនិយមទៅទស្សនាពេលរសៀលម៉ោង ២ ដើម្បីមើលទិដ្ឋភាពឲ្យបានច្រើន និងផ្ទាំងទស្សនីយភាពទុកជាអនុ-ស្សាវរីយ៍ ហើយអង្គុយរហូតដល់ព្រលប់ទើបត្រឡប់ទៅផ្ទះវិញ ។ ប្រាសាទអង្គរជាប់ឈ្មោះល្បីល្បាញ បានទាក់ទាញភ្ញៀវទេសចរជាតិ-អន្តរជាតិចម្រុះជាតិសាសន៍ទៅទស្សនា តំបន់នោះក្លាយជាតំបន់ឧស្សាហកម្មគ្មានផ្សែង ធ្វើឲ្យសេដ្ឋកិច្ចអ្នកនៅក្នុងតំបន់ ក៏ដូចជាសេដ្ឋកិច្ចជាតិមានការរីកចម្រើនមួយកម្រិត ព្រមទាំងធ្វើឲ្យពួកភ្ញៀវទេសរចរអន្តរជាតិមានការកោតស្ញប់ស្ញែងពីស្នាដៃបុព្វបុរសខ្មែរ និងវប្បធម៌ដ៏រុងរឿងពីអតីតកាលមិនចាញ់បណ្ដាបរទេសជិតខាងឡើយ ៕

*(ដកស្រង់ពីកាសែតកោះសន្តិភាពចេញផ្សាយថ្ងៃទី១៤ ខែមីនា ឆ្នាំ ២០០៦)*

**កំណាព្យ**

# ជីវិតជាទាហានអាមេរិក

ខ្មែរក្រោមពីដើមជាទាហាន
ស្លាប់រស់គឺគ្មាននរណាដឹង
អ្នកស្លាប់គឺបាត់ដំណឹងឈឹង
អ្នករស់យួនដឹងគេធ្វើបាប ។

អាមេរិកចុះចាញ់យួនឡើងថ្កើង
ទាហានខ្មែរយើងសែនយ៉ឺនយ៉ាប់
អ្នកខ្លះត្រូវយួនពួនសម្លាប់
អ្នកខ្លះខ្លាចស្លាប់ដុតច្បាប់ចោល ។

អ្នកខ្លះតាំងខ្លួនជាកសិករ
លាបពណ៌លឺចបកាន់នង្គ័ល
ដឹងថាខ្លួនចាញ់បាត់ស្រមោល
ជីវិតតែលគោលសូមត្រឹមរស់ ។

ជាច្រើនទសវត្សរ៍ណាស់មកហើយ
អាមេរិកអើយអ្នកទៅហួស
ទុកឲ្យខ្មែរក្រោមនៅរងគ្រោះ
គឺរស់យួនចាត់ជាសត្រូវ ។

សត្រូវពីតាដល់មកកូន
គឺសូន្យក្បៀសសូន្យកែលែងត្រូវ
ខ្ញុំសូមលើកឡើងនូវរឿងរ៉ាវ
ដែលនៅបច្ចុប្បន្នមកថ្លែងចារ ។

អ្នកជាប់ស្រឡាយជាទាហាន
អាមេរិកគឺគ្មានបានធ្វើការ
ដ្បិតអីកុម្មុយនិស្តយួនរដ្ឋា
តែងស៊ើបសាវតារតាមដៅពង្ស ។

ម៉្យាងទៀតសិស្សអន្តេវាសិក
ខ្មែរច្រើនសន្ធឹកដែលជាប់វង្ស
ពង្សអ្នកទាហានជាយូរលង់
ដល់ប្រាប់យួនត្រង់គេដេញចេញ ។

គិតទៅទាហានអាមេរិក
គ្រប់ពេលបើកម្មេចតែងទោម្មេញ
ដ្បិតអីរដ្ឋយួនគេផ្ដាលផ្ដាញ់
គេក្នាញ់ស្រឡាយពួកអស់នេះ ។

ដូច្នេះខ្មែរក្រោមពិតកម្សត់
កើតទុក្ខប្រាកដឥតមានលេស
បើអ្នកបានដឹងដំណឹងនេះ
គួរត្រិះរិះរកឧបាយស្រង់ ។

ខ្ញុំជាកូនខ្មែរខ្សែអាមេរិក
រង់ចាំជានិច្ចភាពផូរផង់
ត្រូវអាមេរិកជួយមិនបង្អង់
តម្រង់ទិសដៅតាមភាពពិត ។

កុំឲ្យអ្នកខ្សោយដូចខ្មែរខ្ញុំ
ត្រូវយំមិនចេញក្នាញ់ក្នុងចិត្ត
ព្រោះតែស្រឡាយទាហានពិត
អាមេរិកមិនគិតត្រូវទឹកភ្នែក ៕

**ដោយ: ទិត្ថ វិដ្ឋល**

# កំទេចភ្លើងមួយដ៏តូច

កំទេចភ្លើងដ៏តូចមួយ អាចធ្វើឲ្យរដ្ឋាភិបាលក្រុងហាណូយភ្ញាក់ឡើងលើផ្ទាស ការសាមគ្គី ការរួបរួមគ្នា ការមូលមតិជាធ្លុងមួយ គឺជាមធ្យោបាយមួយដ៏ចំណានបំផុត ។ រាប់ទសវត្សរ៍មកហើយ ដែលខ្មែរកម្ពុជាក្រោមយើងរស់នៅក្រោមចក្រពត្តិយួនកុម្មុយនិស្ត រងទុក្ខលំបាកវេទនាស្ទើររលាយពូជសាសន៍ វប្បធម៌ ទំនៀមទំលាប់ សាសនា បាត់អស់ពីពិភពលោកទៅហើយ ។ ដូច្នេះ បច្ចុប្បន្នខ្មែរក្រោមយើងមានសហព័ន្ធជាគោលដៅ សំរាប់ដឹកនាំនាវាខ្មែរក្រោមឆ្ពោះទៅកាន់ទិសដៅតែមួយគត់ គឺទាមទារសម្រេចវាសនាខ្លួនដោយខ្លួនឯង ពីព្រោះខ្មែរយើងជាម្ចាស់ស្រុក ជាម្ចាស់ដី ជាម្ចាស់សាសនា ។ យួនគឺចោរព្រៃឈ្លានពានលួចប្លន់ ទឹកដីកម្ពុជាក្រោមរបស់ខ្មែរ ដូច្នេះ យួនត្រូវតែសងទឹកដីឲ្យមកខ្មែរវិញជាដាច់ខាច កុំភ្លេចថា កំទេចភ្លើងដ៏តូចនេះ អាចធ្វើឲ្យឆាបឆេះក្រុងហាណូយបាន អាស្រ័យដោយយើងសាមគ្គីគ្នាជាធ្លុងមួយ ដើម្បីឈានឡើងទៅកាន់ឧត្តមភាព ភាតរភាព សមភាព ។

សូម្បីសត្វអសិរពិសដ៏តូចមួយ វាអាចប្រហារសត្វដំរីស្លាប់នឹងកន្លែងបានដោយងាយស្រួលបំផុត អាស្រ័យដោយពិសរបស់វា ។ យ៉ាងណាមិញសហព័ន្ធខ្មែរកម្ពុជាក្រោម ក៏អាចអូសក្បាលរដ្ឋាភិបាលក្រុងហាណូយឡើងតុលាការអន្តរជាតិបានដែរ ។ សូមជនរួមជាតិកុំឆ្ងល់ ហេតុអ្វីវៀតណាមខំប្រឹងកសាងប្រទេសខ្លាំងម្ល៉េះ ? ទង្វើទាំងនេះ គឺយួនកសាងសងឲ្យខ្មែរយើងវិញតែប៉ុណ្ណោះឯង នេះនិយាយឲ្យស្រណុកស្តាប់ ។

សូមជនរួមឈាម ក្រឡេកមើលប្រទេសឥណ្ឌូស៊ីយ៉ាងណា ? កោះតៃវ៉ាន់យ៉ាងណា ? យ៉ាងណាមិញកម្ពុជាក្រោមក៏ដូច្នោះដែរ ។ យើងសូមបញ្ជាក់យ៉ាងច្បាស់ថា អ្នកនយោបាយដើរត្រឡប់ក្រោយគេមិននិយាយដល់ឡើយ ដំណើរវិវឌ្ឍន៍តែមួយគត់របស់អ្នកនយោបាយ គឺជាគោលដៅរបស់ពួកគេ ចូរកុំមានចម្ងល់ឲ្យសោះ ។ យួនយកទឹកដីកម្ពុជាក្រោម កសាងសេដ្ឋកិច្ចយូរណាស់ហើយ ដូច្នេះយួនត្រូវតែកសាងទុកឲ្យយើងវិញ ឯករាជ្យនឹងមានដល់យើងជាក់មិនខានឡើយ ប្រទេសណាក៏ដោយឲ្យតែចូលជាសមាជិកអង្គការ UNPO ហើយ ឯករាជ្យនឹងកើតមានដល់ប្រទេសនោះមិនខាន ។

សហព័ន្ធខ្មែរកម្ពុជាក្រោម ទាមទារឯករាជ្យ យុត្តិធម៌ដោយអហិង្សា ដោយសន្តិវិធី ដោយស្របតាមច្បាប់អន្តរជាតិ ស្រឡាញ់សិទ្ធិសេរីភាព និងគោរពសិទ្ធិមនុស្ស ។ វត្ថុអ្វីក៏ដោយ ដែលកើតឡើងអំពីធម្មជាតិ មានទឹក ដី ភ្លើង ខ្យល់ ជាទីបំផុតត្រូវតែសងទៅធម្មជាតិវិញជាពុំខាន ។ វាមិនលែងឡើយ យួនយកដីខ្មែរ ត្រូវតែសងឲ្យខ្មែរវិញអីចឹង ដែរ គឺមិនខុសគ្នាឡើយ ។ យួនឈ្លានពានដីខ្មែរចាប់តាំងពីឆ្នាំ ១៦២៣ រហូតមកដល់ពេលនេះ គឺវាល្មមគ្រប់គ្រាន់ណាស់ហើយ ការសម្លាប់ខ្មែរ រំលាយពូជសាសន៍ខ្មែរ លុបបំបាត់ភស្តុតាងភូមិសាស្ត្រ ប្រវត្តិសាស្ត្រ អក្សរសាស្ត្រ និងវប្បធម៌ខ្មែរ ពេលនេះសូមសងកំហឹងឲ្យយួនម្តងវិញ ធ្វើឲ្យយួនចាញ់ទាំងអាម៉ាសទូទាំងពិភពលោក ធ្វើឲ្យពិភពលោកស្គាល់ចោរយួនព្រៃផ្សៃ អមនុស្សធម៌ ទុយ៌ស ទមិឡអន្យតិរ្ថិយ ជនគ្មានសាសនា គំនិតរបិលរប៉ូចដូចជាសត្វស្វា ដែលកូនចៅរបស់មេចោរហោជីមិញ ។

ឥឡូវនេះ គឺជាពេលវេលាដែលពួកយួនត្រូវហូរទៅហាណូយវិញហើយ មិនត្រូវស្ថិតនៅជាប់ដែនដីសណ្តទន្លេមេគង្គទៀតទេ ពីព្រោះពេលនេះច្បាប់អន្តរជាតិមានហើយ UNPO ជាឪពុកម្តាយរបស់ជនជាតិដើមក៏មានហើយដែរ ។ ចំណែកឯអ្នកទោស ដែលជាប់ពាក់ព័ន្ធជាមួយនឹងទឹកដីកម្ពុជាក្រោម ត្រូវតែមានការទទួលខុសត្រូវចំពោះជោគវាសនារបស់ខ្មែរក្រោម ដោយមិនអាចប្រកែកបានជាដាច់ខាត ។

ប្រទេសជាអ្នកទទួលខុសត្រូវ ចំពោះបញ្ហាទឹកដីកម្ពុជាក្រោម ព្រៃនគរ កោះត្រល់ គឺបារាំងជាអ្នកទទួលខុសត្រូវ ពីព្រោះបារាំងជាអ្នកកាត់ទឹកដីកម្ពុជាក្រោមឲ្យទៅយួនបាវដាយ កាលពីថ្ងៃទី ៤ មិថុនា ឆ្នាំ ១៩៤៩ ដូច្នេះហើយ អាណានិគមបារាំង ជាអ្នកទទួលខុសត្រូវតែមួយគត់ ចំពោះការប្រគល់ទឹកដីកម្ពុជាក្រោមដោយមិនបានសួរយោបល់ពីខ្មែរក្រោមម្ចាស់ទឹកដីឲ្យទៅយួន សឲ្យខ្លីមក បារាំងជាអ្នកទោសទីមួយ យួនជាអ្នកទោសទីពីរ ដូច្នេះតុលាការក្រុងឡាអេ នឹងរីករាយរង់ចាំស្វាគមន៍អ្នកទាំងពីរ នៅទីក្រុងឡាអេខាងមុខនេះ ៕

**ចៅ សារៈឥន្ទ**

# សេចក្តីអំពាវនាវ

## ជួយឧបត្ថម្ភសន្និសីទអន្តរជាតិស្តីពីកម្ពុជាក្រោម

សហព័ន្ធខ្មែរកម្ពុជាក្រោម នឹងរៀបចំសន្និសីទអន្តរជាតិស្តីពីបញ្ហាកម្ពុជាក្រោម នៅថ្ងៃទី ២៥-២៧ ខែសីហា ឆ្នាំ ២០០៦ នៅទីក្រុងឡាអេ ប្រទេសហូឡង់ ។

ខ្មែរក្រោម បានរស់នៅក្រោមនឹមអាណានិគមជាច្រើនទសវត្សរ៍មកហើយ ចាប់តាំងពីជនជាតិយួនចូលរុករានទន្ទ្រានឈ្លានពានធ្វើអាណានិគម លើទឹកដីកេរមរតកនៃយើង ។

អាណានិគមបារាំងបានរំលោភបំពានយកទឹកដីកម្ពុជាក្រោមជាកម្មសិទ្ធិរបស់ខ្លួន ទោះបីគ្មានការអនុញ្ញាតពីពលរដ្ឋខ្មែរដែលជាម្ចាស់ស្រុកនោះក៏ដោយ ។ ជាអំពើអយុត្តិធម៌មួយ ដែលរដ្ឋាភិបាលបារាំងបានឃុបឃិតជាមួយអធិរាជយួនបាវដាយ ប្រគល់ទឹកដីកម្ពុជាក្រោមទាំងស្រុងឲ្យទៅយួនបន្តធ្វើអាណានិគម ។

ដើម្បីឲ្យមានការគាំទ្រតាមផ្លូវច្បាប់ និងស្របទៅតាមច្បាប់អន្តរជាតិស្តីពីបញ្ហាអាណានិគមនោះ សហព័ន្ធខ្មែរកម្ពុជាក្រោមដោយមានការគាំទ្រពីអង្គការ យូអិនភីអូផងនោះ បានរៀបចំឲ្យមានសន្និសីទអន្តរជាតិមួយស្តីពីកម្ពុជាក្រោម ។ ក្នុងគោលបំណងប្រមែប្រមូលឯកសារត្រឹមត្រូវ ដោយមានការគាំទ្រពីសំណាក់អ្នកឯកទេសច្បាប់អន្តរជាតិស្តីពីអាណានិគម សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ស្វ័យភាព សិទ្ធិមនុស្ស ឧក្រិដ្ឋកម្ម និងប្រវត្តិសាស្ត្រកម្ពុជាក្រោម ។

អាស្រ័យហេតុនេះ យើងខ្ញុំសូមអំពាវនាវដល់ជនរួមឈាមខ្មែរស្នេហាជាតិគ្រប់ស្រទាប់ និងគ្រប់និន្នាការនយោបាយ សូមមេត្តាជួយផ្តល់វិភាគទានដើម្បីជំរុញឲ្យសន្និសីទកម្ពុជាក្រោមបានទទួលជោគជ័យ ។

សូមមេត្តាទំនាក់ទំនងមកសមាគម ឬសាខាសហ-ព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក ឬលោក ត្រឹង យ៉ាប តាមអាស័យដ្ឋាន និងទូរស័ព្ទដូចខាងក្រោម៖

Office of Treasurer

P. O Box 193, Pennsauken, NJ 08110 U. S. A

Tel: (856) 655 3838

Fax: (856) 583 1503

សូមអរព្រះគុណ និងសូមអរគុណ !

ប្រធានប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោម

**ថាច់ ង៉ុក ថាច់**




**-វិទ្យុសំឡេងកម្ពុជាក្រោម** ជាសំឡេងរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ផ្សាយចេញពីក្រុងវ៉ាស៊ីនតោន រដ្ឋធានីនៃ សហរដ្ឋអាមេរិក សម្រាប់បម្រើដល់ប្រិយមិត្តអ្នកនិយមស្តាប់ការផ្សាយរបស់វិទ្យុយើងខ្ញុំ ។

**-កម្មវិធីផ្សាយ** ៖ ផ្សាយក្នុងមួយសប្តាហ៍ម្តង រៀងរាល់ថ្ងៃអង្គារ ចាប់ពីម៉ោង ៩ ដល់ម៉ោង ១០ យប់ ម៉ោងនៅកម្ពុជាក្រោម តាមកម្ពស់រលកធាតុអាកាសខ្លី ១៥.៦៩០ គីឡូហឺត ។

-ប្រិយមិត្ត ក៏អាចបើកស្តាប់បានគ្រប់ពេល តាមរយៈគេហទំព័រ www.khmerkrom.org/radio ។

# លិខិតជូនពរឆ្នាំថ្មី ដល់សហព័ន្ធខ្មែរកម្ពុជាក្រោម

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំច អដ្ឋស័ក ព.ស. ២៥៥០ គ.ស. ២០០៦ យើងខ្ញុំជាប្រជាពលរដ្ឋក្លាហាន ដែលស្នេហាយុត្តិធម៌ ស្រឡាញ់សន្តិភាព សេរីភាព ស្អប់ខ្ពើមនូវការជិះជាន់សង្កត់សង្កិន គំរាមកំហែង និងកេងប្រវ័ញ្ចពុករលួយ មានបីតិសោមនស្សរីករាយឥតឧបមា ដោយថ្នាក់ដឹកនាំសហព័ន្ធខ្មែរកម្ពុជាក្រោម លោកខិតខំប្រឹងប្រែងឥតសំចៃ ដើម្បីឲ្យសាធារណៈមតិអន្តរជាតិ មើលធ្ងន់អំពីទុក្ខវេទនាទាំងសព្វគ្រប់របស់ខ្មែរកម្ពុជាក្រោម អាស្រ័យដោយមេដឹកនាំយួនរំលោភបំពានសិទ្ធិសេរីភាពជាមូលដ្ឋាន ។

យើងខ្ញុំប្រជាពលរដ្ឋខ្មែរ បានកំណត់ច្បាស់ថា មានតែសម័យកាលនេះទេ ដែលខ្មែរកម្ពុជាក្រោមយើង មានសហព័ន្ធធ្វើជាបង្អែក ជាស្ពាន ជាចរន្តផ្សារភ្ជាប់ ឬផ្តល់ជូនឲ្យពិភពលោកយល់ដឹងបាននូវអ្វីដែលជាសភាពការណ៍ពិត ហើយកំពុងកើតមានលើទឹកដីកម្ពុជាក្រោម ។ នេះជាមធ្យោបាយដ៏វិសេសវិសាលមួយ ជាក្តីសង្ឃឹម និងជាកត្តាសំខាន់ក្នុងការបំផុសស្មារតីស្នេហាជាតិ ស្នេហាមាតុភូមិរបស់ខ្លួន ដោយខ្មែរគ្រប់រូបត្រូវស្តែងចេញ នូវការទាមទារតស៊ូឲ្យអាណានិគមនិយមយួន ផ្លាស់ប្តូរអាកប្បកិរិយាអពុក្ខាន និងប្រគល់មកវិញរាល់សិទ្ធិសេរីភាពពិត ៗ ជូនដល់ខ្មែរកម្ពុជាក្រោមដែលជាម្ចាស់ស្រុក ធ្លាប់មានគុណបំណាច់លើប្រជាជនយួនស្ទើរគ្រប់ជំនាន់ ។

សាជាថ្មីម្តងទៀត យើងខ្ញុំជាប្រជាពលរដ្ឋស្លូតត្រង់ សូមបួងសួងឲ្យទេវតាឆ្នាំថ្មី ឆ្នាំច អដ្ឋស័ក ព្រះនាម **កិមិរាទេវី** មេត្តាប្រទានពរជ័យ សិរីមង្គល វិបុលសុខ ដ៏បវរមហាប្រសើរជូនដល់អស់លោក ដែលជាថ្នាក់ដឹកនាំ និងសហការីនៃសហព័ន្ធខ្មែរកម្ពុជាក្រោមទាំងមូល ដើម្បីឲ្យអស់លោកមានលទ្ធភាព សមត្ថភាព សម្រេចបាននូវបុព្វហេតុដ៏ឧត្តុង្គឧត្តម និងជាគោលដៅរួម បង្កប់នូវកត្តាសាមគ្គី សំដៅទាមទារសិទ្ធិសេរីភាពពេញលេញ ជូនដល់ខ្មែរកម្ពុជាក្រោមដែលកំពុងរស់លើដែនដីកំណើតដ៏ជាទីស្នេហានៃយើង ៕

ដែនដីសណ្តូ, ថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៦

តំណាងប្រជាជនស្លូតត្រង់

**ចៅ សុផាត**





ព្រះចេតីយ៍ និងខឿនព្រះវិហារវត្តស្វាយសចាស់ ដែលនៅសេសសល់ក្រោយពីត្រូវយួនបំផ្លាញ រឹបអូសយកវត្ត នៅស្រុកស្វាយទង ខេត្តមាត់ជ្រូក